ធនាគារជាតិនៃកម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# ព្រឹត្តិបត្រប្រចាំត្រីមាស

## ត្រីមាសទី១ ឆ្នាំ២០២៦



ចេញផ្សាយតាមប្រកាសលេខ
ធ៦-០១១-១២៣ ប្រ.ក
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១

លេខ ៨៤

# អារម្ភកថា



## លោកជំទាវបណ្ឌិត ជា សិរី
## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

### ប្រិយមិត្តអ្នកអានជាទីមេត្រី!

នាត្រីមាសទី១ ឆ្នាំ២០២៦ សេដ្ឋកិច្ចពិភពលោកកំពុងបន្តប្រឈមនឹងភាពមិនប្រាកដប្រជាកាន់តែខ្លាំងឡើង បន្ទាប់ពីសង្គ្រាមនៅតំបន់មជ្ឈិមបូព៌ាបានផ្ទុះឡើងកាលពីចុងខែកុម្ភៈ ឆ្នាំនេះ ដែលជាកត្តាថ្មីមួយទៀតបន្ថែមលើ ភាពតានតឹងខាងភូមិសាស្ត្រនយោបាយ របាំងពាណិជ្ជកម្ម និងការប្រែប្រួលស្ថានភាពហិរញ្ញវត្ថុ ដែលពិភពលោកបាននិងកំពុងប្រឈមកន្លងមក។ ក្នុងស្ថានភាពនេះ សេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថានឹងថមថយមកវិញ ជាមួយអត្រាកំណើនទាបជាងឆ្នាំមុន ប្រសិនបើសង្គ្រាមនៅបន្តអូសបន្លាយ ខណៈដែលអតិផរណាត្រូវបានរំពឹងថានឹងកើនឡើង ជាពិសេសនៅប្រទេសកំពុងលូតលាស់ និងកំពុងអភិវឌ្ឍ។

សេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២៦ ត្រូវបានព្យាករថានឹងរក្សាកំណើនក្នុងអត្រា ៤,៣% ដែលគាំទ្រដោយភាពរឹងមាំនៃវិស័យកម្មន្តសាលនាំចេញ កំណើនទេសចរណ៍ពីការលើកលែងទិដ្ឋាការដល់ភ្ញៀវទេសចរចិន និងការជំរុញសហគមន៍កសិកម្មទំនើប ទោះបីជាត្រូវប្រឈមនឹងហានិភ័យពីភាពមិនច្បាស់លាស់នៃពន្ធគយអន្តរជាតិ និងភាពតានតឹងនៃជម្លោះព្រំដែន ក៏ដូចជាផលប៉ះពាល់រយៈពេលខ្លីពីការបង្ក្រាបបទល្មើសឆបោកតាមបច្ចេកវិទ្យាក្តី។ អតិផរណារួមមានកម្រិតជាមធ្យម ៣,១% ដែលជាចម្បងបណ្តាលមកពីការកើនឡើងនៃថ្លៃប្រេងឆៅពិភពលោកក្នុងខែមីនា។ ចំណែកឯអត្រាប្តូរប្រាក់ជាមធ្យមប្រចាំខែមានកម្រិត ៤.០១៩ រៀលក្នុងមួយដុល្លារអាមេរិក។

ដើម្បីលើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជាទៅក្នុងតំបន់និងពិភពលោក ធនាគារជាតិនៃកម្ពុជាបន្តអភិវឌ្ឍនិងតភ្ជាប់ការធ្វើអន្តរប្រតិបត្តិការទូទាត់ជាមួយប្រទេសដៃគូក្នុងតំបន់ សំដៅជំរុញ និងសម្រួលសកម្មភាព ពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ និងលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុករវាងប្រទេសក្នុងតំបន់ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត ដែលការណ៍នេះបានរួមចំណែកគាំទ្រកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គមប្រកបដោយចីរភាព។ ជាក់ស្តែង ក្នុងត្រីមាសនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូត រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសិង្ហបុរី (ដំណាក់កាលទី២៖ សិង្ហបុរីស្កេនខេអេចយូអរកូតនៅក្នុងប្រទេសកម្ពុជា)។

## ប្រិយមិត្តអ្នកអានជាទីមេត្រី!

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមផ្សព្វផ្សាយព្រឹត្តិបត្រប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ ដោយរួមបញ្ចូលនូវព័ត៌មានសំខាន់ៗ ដូចជា៖ i/-ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធធនាគារ ii/-បទប្បញ្ញត្តិថ្មីៗ និង iii/-សេចក្តីប្រកាសព័ត៌មាន។ល។ ខ្ញុំសង្ឃឹមថា ព្រឹត្តិបត្រដែលប្រិយមិត្តអ្នកអានទាំងអស់ មាននៅក្នុងដៃនាពេលនេះនឹងរួមចំណែកបង្កើតចំណេះដឹងផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាការស្វែងយល់ពីគោលនយោបាយ និងសកម្មភាពការងារថ្មីៗរបស់ធនាគារជាតិនៃកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា ដែលបាននិងកំពុងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងអស់ដែលបានរួមចំណែកអភិវឌ្ឍវិស័យធនាគារនៅកម្ពុជា ឱ្យរីកចម្រើនឡើងជាលំដាប់ និងបោះជំហានទៅមុខយ៉ាងស្វាហាប់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយភាពរឹងមាំ ចីរភាព និងបរិយាបន្ន។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ សូមជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## សូមអរគុណ!

# មាតិកា

**អារម្ភកថា**.......................................................................................................... i-ii

## ❁ ផ្នែកទី១: រូបថត និងសុន្ទរកថារបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា

១.១. សុន្ទរកថាបើក លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ របស់ធនាគារជាតិនៃកម្ពុជា ......... **១**

១.២. សុន្ទរកថាបិទ លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ របស់ធនាគារជាតិនៃកម្ពុជា ......... **៦**

១.៣. សុន្ទរកថា លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២ ................. **១០**

១.៤. សុន្ទរកថា លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងពិធីសម្ពោធអគារសិក្សា ១ខ្នង ៥បន្ទប់ និងសមិទ្ធផលនានា នៅសាលាបឋមសិក្សាត្រពាំងផ្អៀក ស្ថិតក្នុងឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ........................................................................................ **១៤**

១.៥. សុន្ទរកថា លោកជំទាវបណ្ឌិត ជា សិរី ក្នុងពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយន្តអរកូតរវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសិង្ហបុរី (ដំណាក់កាលទី២៖ សិង្ហបុរីស្កេនខេអេចយូអរកូតនៅក្នុងប្រទេសកម្ពុជា)............................................ **១៨**

១.៦. សុន្ទរកថា ឯកឧត្តម រ័ត្ន សុវណ្ណនរៈ ថ្លែងក្នុងកម្មវិធីបើកវគ្គបណ្តុះបណ្តាលដល់គ្រូបង្គោលនៃគម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍"........................................... **២១**

១.៧. សុន្ទរកថា ឯកឧត្តម យឹម លាត ថ្លែងក្នុងទិវាប្រាក់រៀល ខួបលើកទី៤៦ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ........................................................................ **២៧**

## ❁ ផ្នែកទី២: សេចក្តីប្រកាសព័ត៌មាន

២.១. សេចក្តីជូនដំណឹង ស្តីពីការផ្តល់អាទិភាពសម្របសម្រួលសំណើរបស់យោធិនជួរមុខ សម្រាប់វិធានការជួយសម្រាលបន្ទុកដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជម្លោះព្រំដែនកម្ពុជា-ថៃ . **៣១**

២.២. សេចក្តីជូនដំណឹង ស្តីពីការជម្រះបញ្ជីធនាគារព្រីនស៍ ម.ក........................................... **៣២**

២.៣. សេចក្តីជូនដំណឹង ស្តីពីការលើកលែកសោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំ២០២៦ សម្រាប់សាខាស្រុករបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលមានទីតាំងក្នុងខេត្តព្រះវិហារ បន្ទាយមានជ័យ ឧត្តរមានជ័យ ពោធិ៍សាត់ និងបាត់ដំបង ...... ៣៣

២.៤. សេចក្តីជូនដំណឹង ស្តីពីការកែសម្រួលតម្លៃកាសប្រាក់សុទ្ធស្របតាមការកើនឡើងថ្លៃប្រាក់សុទ្ធលើទីផ្សារ...... ៣៥

២.៥. សេចក្តីប្រកាសព័ត៌មាន ស្តីពីស្ថានភាពមិនស្របច្បាប់របស់កម្មវិធី PAI ឬ PaiPay...... ៣៦

## ❁ ផ្នែកទី៣: សកម្មភាពថ្នាក់ដឹកនាំ

៣.១. លោកជំទាវបណ្ឌិត ជា សិរី និង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហប្រធាននៃអនុគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា (អ.គ.ជ.ស.) ដឹកនាំកិច្ចប្រជុំអនុគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុ ...... ៣៧

៣.២. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូជាន់ខ្ពស់នៃធនាគារកណ្តាលប៉ាពូញូហ្គីណេ ដែលមកបំពេញទស្សនកិច្ចនៅកម្ពុជា ...... ៣៨

៣.៣. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូនៃអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ...... ៤០

៣.៤. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារប្រធានការិយាល័យតំបន់អាស៊ីនិរតីនិងប្រជុំកោះប៉ាស៊ីហ្វិក និងសហការី នៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC).. ៤២

៣.៥. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយលោកស្រី Vladanka Andreeva អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដែលទើបត្រូវបានតែងតាំង និងសហការី ...... ៤៣

៣.៦. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយលោកស្រី Yasmin Siddiqi នាយិកាធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំប្រទេសកម្ពុជា និងសហការី ...... ៤៤

៣.៧. លោកជំទាវបណ្ឌិត ជា សិរី អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់ធនាគារហត្ថា ដឹកនាំដោយលោក Kenichi Yamato តំណាងភាគទុនិក ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ .. ៤៥

៣.៨. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូក្រុមប្រឹក្សាធុរកិច្ចសហភាពអឺរ៉ុប-អាស៊ាន (EU-ABC)...... ៤៦

៣.៩. លោកជំទាវបណ្ឌិត ជា សិរី អនុញ្ញាតឱ្យក្រុមបេសកកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដឹកនាំដោយលោក Kenichiro Kashiwase ប្រធានក្រុមបេសកកម្មសម្រាប់កម្ពុជា ចូលជួបសម្តែងការគួរសម ........ ៤៩

៣.១០. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូធនាគារពិភពលោក ដឹកនាំដោយលោក Carlos Felipe Jaramillo អនុប្រធាន ធនាគារពិភពលោកទទួលបន្ទុកតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក ........ ៥០

៣.១១. លោកជំទាវបណ្ឌិត ជា សិរី អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់ធនាគារចិន ដឹកនាំដោយលោក Sun Yu នាយកប្រតិបត្តិ ធនាគារចិន ប្រចាំទីក្រុងហុងកុង ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ........ ៥១

៣.១២. លោកជំទាវបណ្ឌិត ជា សិរី អនុញ្ញាតឱ្យក្រុមការងារវិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ (IBF) ដឹកនាំដោយលោក វ័ន្ត សោភ័ណ ប្រធានសមាគមធនាគារនៅកម្ពុជា (ABC) ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍នានា ........ ៥២

៣.១៣. លោកជំទាវបណ្ឌិត ជា សិរី និងលោកជំទាវ ខៀវ ស៊ីណា ជា ចាន់តូ អញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់វិទ្យាល័យ ជា ចាន់តូ ........ ៥៣

៣.១៤. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា ១ខ្នង និងអគារបណ្ណាល័យ ១ខ្នង នៅវិទ្យាល័យ ជា ស៊ីម កំពង់ថ្ម ស្ថិតក្នុងឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ........ ៥៤

## ផ្នែកទី៤: តារាង (ភាសាខ្មែរនិងអង់គ្លេស)

៤.១. តារាងអត្រាប្តូរប្រាក់ប្រចាំខែ ........ ៥៥

៤.២. ប្រាក់បញ្ញើនៅធនាគារទទួលប្រាក់បញ្ញើ និងបម្រែបម្រួលប្រចាំខែ ........ ៥៧

៤.៣. ឥណទានផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើតាមវិស័យ ........ ៥៨

៤.៤. ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងអង្គការមិនមែនរដ្ឋាភិបាល ........ ៦០

៤.៥. ការជាត់ទាត់មូលប្បទានបត្រតាមរយៈសភាជាត់ទាត់ ........ ៦១

៤.៦. ប្រព័ន្ធធនាគារកម្ពុជា ........ ៦៣

# សុន្ទរកថាបើក
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥
# និងទិសដៅការងារឆ្នាំ២០២៦ របស់ធនាគារជាតិនៃកម្ពុជា

ថ្ងៃសុក្រ ៥កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦



**សូមគោរព៖**

**-គណៈអធិបតី**

**-ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក និងសូមស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ របស់ធនាគារជាតិនៃកម្ពុជា។ សន្និបាតរបស់យើងត្រូវបានរៀបចំឡើងក្នុងពេលវេលាមួយ ដែលប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងស្ថានភាពនៃបទឈប់បាញ់ដែលមានភាពផុយស្រួយនៅឡើយ។

ខ្ញុំសូមយកឱកាសនេះ សម្តែងនូវការដឹងគុណនិងកោតសរសើរបំផុតចំពោះវីរៈកងទ័ពទាំងអស់ ដែលបានបំពេញភារកិច្ចនៅសមរភូមិក្នុងកិច្ចការពារអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី ស្របពេលដែលប្រជាជនខ្មែរទូទាំងប្រទេសក៏បានរួមចំណែកយ៉ាងសកម្មក្នុងការកៀរគរមូលនិធិ ស្បៀងអាហារ និងសម្ភារៈចាំបាច់ផ្សេងៗ ដើម្បីផ្គត់ផ្គង់ទៅដល់ជំរំជនភៀសសឹកនានា ដែលបានឆ្លុះបញ្ចាំងពីឆន្ទៈស្នេហាជាតិនិងសាមគ្គីភាពយ៉ាងរឹងមាំរបស់ប្រជាជនយើង ដូចប្រសាសន៍ដ៏ថ្លៃថ្លានិងប្រកបដោយអត្ថន័យរបស់ **សម្តេចតេជោ** ដែលបានលើកឡើងថា "សាមគ្គីរស់ សាមគ្គីឈ្នះ"។

ក្នុងស្មារតីនេះ យើងទាំងអស់គ្នាបន្តជឿជាក់ និងគាំទ្រឥតងាករេចំពោះរាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងតាមរយៈមធ្យោបាយសន្តិវិធី ការសន្ទនានិងការចរចារផ្នែកការទូត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ស្ថិតក្នុងភាពមិនប្រាកដប្រជាខ្ពស់ ដោយសារស្ថានភាពភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ចដែលបន្តមានសភាពតានតឹង និងលក្ខខណ្ឌហិរញ្ញវត្ថុអន្តរជាតិរឹតត្បិត នៅឆ្នាំ២០២៥ សេដ្ឋកិច្ចពិភពលោកត្រូវបានប៉ាន់ស្មានថាមានកំណើនយឺត។ សម្រាប់កម្ពុជា បើទោះជាមានកំណើនទាបជាងឆ្នាំ២០២៤ និងការរំពឹងទុកកាលពីដើមឆ្នាំ២០២៥ សេដ្ឋកិច្ចត្រូវបានប៉ាន់ស្មានថាសម្រេចបានកំណើន ៥% ដែលត្រូវបានគាំទ្រជាចម្បងដោយកំណើននៃការនាំចេញទាំងផលិតផលកម្មន្តសាលកាត់ដេរ និងមិនមែនកាត់ដេរ។ អតិផរណាជាមធ្យមបានកើនឡើងបន្តិចមកកម្រិត ២,៥% ស្របពេលដែលតម្លៃប្រាក់រៀលក៏ត្រូវបានរក្សាឱ្យមានស្ថិរភាពក្នុងអត្រាជាមធ្យម ៤.០១១ រៀលក្នុងមួយដុល្លារអាមេរិក ដែលបានរួមចំណែកក្នុងការរក្សាស្ថិរភាពថ្លៃទំនិញ និងសេវាទូទៅនៅលើទីផ្សារផងដែរ។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការគ្រប់គ្រងទុនបម្រុងអន្តរជាតិប្រកបដោយប្រសិទ្ធភាពបានធ្វើឱ្យទុនបម្រុងអន្តរជាតិកើនឡើង ២២,៣% ដល់ ២៧,៥ ប៊ីលានដុល្លារអាមេរិក ស្មើនឹងប្រមាណ ៨ខែនៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ ដែលត្រូវបានបន្តចាត់ទុកថាមានកម្រិតខ្ពស់សមស្រប។




ក្នុងពេលដែលសេដ្ឋកិច្ចកំពុងជួបប្រទះនឹងបញ្ហាប្រឈមទាំងពីខាងក្រៅ និងក្នុងស្រុក ប្រព័ន្ធធនាគារបន្តរួមចំណែកគាំទ្រសកម្មភាពសេដ្ឋកិច្ច។ ជាក់ស្តែង ឥណទានដែលផ្តល់ដោយប្រព័ន្ធធនាគារបន្តកើនឡើងសន្សឹមៗក្នុងអត្រា ៤,១% ខ្ពស់ជាងឆ្នាំ២០២៤ ដែលរួមចំណែកគាំទ្រដោយកំណើនតម្រូវការទុននៃសហគ្រាសធុនមីក្រូ តូច និងមធ្យមក្នុងការពង្រីកអាជីវកម្ម។ ដោយឡែក ប្រាក់បញ្ញើបានបន្តកើនឡើងល្អប្រសើរ ជាមួយនឹងអត្រាកំណើន ១៤,៧% គួបផ្សំនឹងស្ថានភាពរឹងមាំនៃដើមទុននិងលទ្ធភាពខ្ពស់ក្នុងការបញ្ចេញសាច់ប្រាក់ដែលបង្ហាញថា ប្រព័ន្ធធនាគារនៅតែមានភាពធន់ និងបន្តទទួលបានជំនឿទុកចិត្តពីសាធារណជន។

ក្នុងស្មារតីសាមគ្គីភាព មនុស្សធម៌ និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជួយសម្រាលបន្ទុកដល់យោធិននៅសមរភូមិ និងប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជម្លោះព្រំដែនកម្ពុជា-ថៃ

ធនាគារជាតិនៃកម្ពុជាបានណែនាំឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញសម្រាប់អតិថិជនទូទៅ ជនភៀសសឹក ពលករត្រលប់មកពីប្រទេសថៃនិងយោធិនដែលធ្វើប្រតិបត្តិការដោយផ្ទាល់ក្នុងសមរភូមិប្រយុទ្ធ ព្រមទាំងផ្តល់ការអនុគ្រោះផ្សេងទៀតដូចជា ការលុបចោលឥណទានរហូតដល់ ៨០ លានរៀលសម្រាប់យោធិនពលី និង ១០ លានរៀល សម្រាប់យោធិនពិការ និងការលើកលែងកម្រៃ ការផាកពិន័យ និងការប្រាក់ព្រមទាំងពន្យារពេលទូទាត់សងប្រាក់ដើម។ ជាមួយគ្នានេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តរៀបចំឥណទានឡើងវិញ ជូនដល់អតិថិជន ដែលបច្ចុប្បន្នមានចំនួន ៥,៣ ប៊ីលានដុល្លារអាមេរិកស្មើនឹង ៨,៣% នៃឥណទានសរុប សម្រាប់គណនីចំនួន ២៥៣ ពាន់។ បន្ថែមពីនេះ ក្នុងបរិបទដែលវិស័យអចលនទ្រព្យមានភាពទន់ខ្សោយ និងដើម្បីសម្រួលដល់អ្នកអភិវឌ្ឍអចលនទ្រព្យនិងអតិថិជនបង់រំលស់ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្នុងការសម្របសម្រួលដល់អតិថិជនដែលបង់រំលស់ដោយផ្ទាល់ជាមួយក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ ឱ្យទទួលបានបុនហិរញ្ញប្បទានពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាមួយនឹងលក្ខខណ្ឌឥណទានអំណោយផល។




**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ក្នុងគោលដៅគាំទ្រក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឱ្យកាន់តែទំនើប សម្បូរបែប និងសុវត្ថិភាព ទាំងការទូទាត់ឆ្លងគ្រឹះស្ថានក្នុងស្រុក និងការទូទាត់ឆ្លងដែន ជាមួយបណ្តាប្រទេសនានានៅក្នុងតំបន់ និងក្រុមហ៊ុនបណ្តាញទូទាត់អន្តរជាតិផ្សេងៗ ដើម្បីបង្កើនជម្រើសក្នុងការទូទាត់ឆ្លងដែន ព្រមទាំងចូលរួមគាំទ្រវិស័យទេសចរណ៍ ពាណិជ្ជកម្មអន្តរជាតិ និងការផ្ទេរប្រាក់របស់ពលករទេសន្តរប្រវេសន៍។

ទន្ទឹមនឹងការទទួលបានអត្ថប្រយោជន៍ពីបច្ចេកវិទ្យាហិរញ្ញវត្ថុ ការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាបាន និងកំពុងក្លាយជាបញ្ហាប្រឈមស្មុគស្មាញ និងគួរឱ្យព្រួយបារម្ភមួយសម្រាប់តំបន់និងពិភពលោក។ ការផ្សព្វផ្សាយអវិជ្ជមានពីកម្ពុជាពាក់ព័ន្ធនឹងបញ្ហាឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា បានបង្កជាហានិភ័យមកលើកេរ្តិ៍ឈ្មោះប្រទេសដែលអាចប៉ះពាល់ក្នុងកម្រិតមួយដល់វិស័យទេសចរណ៍ ទំនុកចិត្តរបស់វិនិយោគិន និងការធ្វើប្រតិបត្តិការ

ហិរញ្ញវត្ថុឆ្លងដែន។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការម៉ឺងម៉ាត់ ដើម្បីទប់ស្កាត់ការរីកសាយភាយនៃសកម្មភាពទាំងនេះ តាមរយៈការចុះបង្ក្រាបតាមអគារកាស៊ីណូខុសច្បាប់ ទីតាំងជម្រកសកម្មភាពឆបោកអនឡាញ និងមានវិធានការតឹងរឹងលើឧក្រិដ្ឋជន។ ធនាគារជាតិនៃកម្ពុជា ដោយមានកិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធក៏បានដកអាជ្ញាបណ្ណរបស់គ្រឹះស្ថានពាក់ព័ន្ធ និងសម្របសម្រួលការបង្កកទ្រព្យសម្បត្តិបុគ្គលពាក់ព័ន្ធតាមដីការតុលាការ។

ដើម្បីប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) បាននិងកំពុងពង្រឹងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រទេសដៃគូនានា ក្នុងការស៊ើបអង្កេត និងការបង្ក្រាបបណ្ដាញឧក្រិដ្ឋជនអន្តរជាតិឱ្យមានប្រសិទ្ធភាព សំដៅរួមចំណែកពង្រឹងប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងបង្កើនជំនឿទុកចិត្តពីសាធារណជន វិនិយោគិនជាតិនិងអន្តរជាតិមកលើសុចរិតភាពនៃប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកនៅក្នុងគំនិតផ្ដួចផ្ដើមសំខាន់ៗក្នុងការលើកកម្ពស់ហិរញ្ញប្បទានប្រកបដោយចីរភាព និងបានចូលរួមអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងបរិស្ថាន សង្គម និងអភិបាលកិច្ច ស្របតាមយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់អព្យាក្រឹតភាពកាបូន និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០២៥-២០៣០ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥។ គួរបញ្ជាក់ថា យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ២០២៥-២០៣០ ត្រូវបានធ្វើបច្ចុប្បន្នកម្មដោយគិតគូរពីអាទិភាពបន្ទាន់នៃការអភិវឌ្ឍ និងនិន្នាការចម្បងៗដែលបាននិងកំពុងកើតឡើងជាសកលចំពោះវិស័យហិរញ្ញវត្ថុជាពិសេស ដំណើរការទៅកាន់ការប្រើប្រាស់ឌីជីថល និងការអភិវឌ្ឍប្រកបដោយចីរភាព។

ក្នុងពេលជាមួយគ្នានេះ ការអភិវឌ្ឍធនធានមនុស្សលើជំនាញបច្ចេកទេសធនាគារក៏ត្រូវបានយកចិត្តទុកដាក់និងបន្តលើកកម្ពស់ជាអាទិភាព។ ទន្ទឹមនេះ សារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ ព្រះស្រីឰសានវរ្ម័ន បានបន្តចូលរួមយ៉ាងសកម្មក្នុងការផ្ដល់ចំណេះដឹងហិរញ្ញវត្ថុ និងសេដ្ឋកិច្ចដល់សាធារណជន និងសិស្សានុសិស្ស ដោយមានភ្ញៀវចូលទស្សនាសរុបចំនួន ៤៣.៤៨៥នាក់ ដែលក្នុងនោះរួមមានទាំងភ្ញៀវជាតិ និងអន្តរជាតិ ហើយសិស្សានុសិស្សមកពីបណ្ដាខេត្តនានា ក៏មានឱកាសចូលទស្សនាសារមន្ទីរផងដែរ។

គួររំលេចថា ជាមួយនឹងសមិទ្ធផលជាច្រើនដែលបានរៀបរាប់ខាងលើ ធនាគារជាតិនៃកម្ពុជាត្រូវបានទទួលស្គាល់ និងផ្ដល់ពានរង្វាន់កិត្តិយស ដោយស្ថាប័នអន្តរជាតិជាច្រើនក្នុងឆ្នាំ២០២៥នេះ។ ជាក់ស្ដែង ធនាគារជាតិនៃកម្ពុជា បានទទួលចំណាត់ថ្នាក់ខ្ពស់ជាងគេផ្នែកសេវាហិរញ្ញវត្ថុនៅក្នុងតំបន់អាស៊ាន ក្នុងរបាយការណ៍ស្ទង់មតិ Business Ready (B-READY) ២០២៥ ដែលចេញដោយធនាគារពិភពលោក។ ការទទួលស្គាល់នេះ គឺផ្អែកលើកត្តាមួយចំនួនដូចជា ប្រសិទ្ធភាពនៃបទប្បញ្ញត្តិនិងការផ្ដល់អាជ្ញាបណ្ណ ហេដ្ឋារចនាសម្ព័ន្ធនិង

ការគ្រប់គ្រងព័ត៌មានឥណទាន នវានុវត្តន៍ឌីជីថល និងការអនុវត្តដោយជោគជ័យនៃប្រព័ន្ធបាគង ដែលបានជំរុញឱ្យការទូទាត់ប្រាក់តាមអេឡិចត្រូនិកកាន់តែមានប្រសិទ្ធភាព។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

ដើម្បីជ្រាបពីសមិទ្ធផលលម្អិត ដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន និងទិសដៅការងារសំខាន់ៗ ខ្ញុំសូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្ដាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំយើងដែលនឹងរាយការណ៍ជូនអង្គសន្និបាតនាពេលបន្តិចទៀតនេះ។ សន្និបាតថ្ងៃនេះក៏នឹងមានពិធីប្រគល់គ្រឿងឥស្សរិយយស មេដាយមាស និងសញ្ញាមាសអនុស្សាវរីយ៍ ផងដែរ ជូនដល់មន្ត្រីបុគ្គលិកយើង ដែលជាការទទួលស្គាល់របស់រាជរដ្ឋាភិបាលចំពោះស្នាដៃនិងសមិទ្ធផលសម្រេចបានដោយធនាគារជាតិនៃកម្ពុជា។ ខ្ញុំសូមជូនពរឱ្យអង្គសន្និបាតរបស់យើងប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងផ្លែផ្កា។

ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**



# សុន្ទរកថាបិទ
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ របស់ធនាគារជាតិនៃកម្ពុជា

ថ្ងៃសុក្រ ៥កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦



**សូមគោរព៖**

- **គណៈអធិបតី**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

នាពេលនេះ សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ របស់ធនាគារជាតិនៃកម្ពុជា បានឈានដល់ទីបញ្ចប់ប្រកបដោយជោគជ័យ។ ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលសន្និបាតពេញមួយថ្ងៃនេះបានប្រព្រឹត្តទៅដោយពិលាសក្រោមបរិយាកាសសាមគ្គីភាព និងភាតរភាព។ ខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងសមាជិក-សមាជិកាអង្គសន្និបាតទាំងអស់ ដែលបានធ្វើបទអន្តរាគមន៍យ៉ាងក្បោះក្បាយនិងត្រង់ត្រាប់ស្តាប់យ៉ាងយកចិត្តទុកដាក់ ដើម្បីស្វែងយល់កាន់តែច្បាស់ពីការវិវឌ្ឍថ្មីៗនៃស្ថានភាពសេដ្ឋកិច្ចជាតិនិងអន្តរជាតិ ក៏ដូចជាលទ្ធផលនិងទិសដៅការងារចម្បងៗសម្រាប់យកទៅអនុវត្តនាពេលខាងមុខ។

ខ្ញុំសូមវាយតម្លៃខ្ពស់ និងសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកយើងទាំងអស់ ដែលបានយកចិត្តទុកដាក់បំពេញការងារ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានសាមគ្គីភាពរឹងមាំ ដោយទទួលបានលទ្ធផលល្អប្រសើរក្នុងការរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារ និងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ។

សមិទ្ធផលទាំងនេះ អាចសម្រេចទៅបាននៅក្នុងស្ថានភាពដែលរាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអនុវត្តនូវគោលនយោបាយត្រឹមត្រូវ និងទាន់ពេលវេលា ជាពិសេសលើការដាក់ពន្ធគយបដិការរបស់សហរដ្ឋអាមេរិក និងទៅលើសង្គ្រាមឈ្លានពានរបស់ប្រទេសថៃមកលើកម្ពុជាតាមរយៈការសន្ទនានិងការទូត ក្នុងការការពារអធិបតេយ្យភាពនិងបូរណភាពដែនដី។ កិច្ចខិតខំប្រឹងប្រែងទាំងនេះបានរួមចំណែកយ៉ាងសំខាន់ ក្នុងការរក្សាបរិយាកាសស្ថិរភាពសម្រាប់សកម្មភាពសេដ្ឋកិច្ច បង្កើនទំនុកចិត្តវិនិយោគិន និងការរស់នៅប្រកបដោយសុវត្ថិភាព

របស់ប្រជាពលរដ្ឋ។ ការណ៍នេះបានបញ្ជាក់យ៉ាងច្បាស់ថា ការអភិវឌ្ឍប្រកបដោយចីរភាព មិនអាចផ្ដាច់ចេញពីសន្តិភាព និងស្ថិរភាពបានឡើយ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

នាឆ្នាំ២០២៦ មូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករថាកំណើនសេដ្ឋកិច្ចពិភពលោកនឹងបន្តរក្សាបានក្នុងល្បឿន ៣,៣% ដែលគាំទ្រដោយការកើនឡើងការវិនិយោគក្នុងវិស័យបច្ចេកវិទ្យា រួមទាំងបញ្ញាសប្បនិម្មិត ការបន្តអនុវត្តនយោបាយសារពើពន្ធនិងរូបិយវត្ថុវត្ថុរលកម្មដែលអំណោយផលដល់ស្ថានភាពហិរញ្ញវត្ថុ និងការសម្របខ្លួនបានរបស់វិស័យឯកជន។ អតិផរណាជាសកលត្រូវបានរំពឹងថានឹងថមថយបន្ថែមទៀត ប៉ុន្តែការវិលទៅរកអតិផរណាគោលដៅអាចស្ថិតក្នុងល្បឿនយឺត ដែលអាចធ្វើឱ្យធនាគារកណ្ដាលចម្បងៗបន្ថយអត្រាការប្រាក់គោលរបស់ខ្លួនដោយប្រុងប្រយ័ត្ន។ ម្យ៉ាងទៀត សេដ្ឋកិច្ចពិភពលោកអាចប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ ដោយសារជម្លោះប្រដាប់អាវុធបាននិងកំពុងកើតឡើងស្ទើរគ្រប់តំបន់ និងនិន្នាការអនុវត្តគោលនយោបាយពាណិជ្ជកម្មគាំពារនិយម បន្ថែមលើហានិភ័យនៃការប្រែប្រួលអាកាសធាតុ។




ក្នុងបរិការណ៍នេះ សេដ្ឋកិច្ចកម្ពុជាអាចនឹងប្រឈមហានិភ័យខាងក្រៅខ្ពស់នៅឆ្នាំ២០២៦។ ទន្ទឹមនេះ កម្ពុជាក៏មានបន្តមានបញ្ហាប្រឈមខាងក្នុងមួយចំនួនផងដែរ រួមមានភាពទន់ខ្សោយនៃវិស័យសំណង់និងអចលនទ្រព្យ និងផលប៉ះពាល់ពីការអូសបន្លាយនៃជម្លោះព្រំដែនកម្ពុជា-ថៃ។ ជាមួយគ្នានេះ ប្រព័ន្ធធនាគារបន្តមានកំណើនឥណទានក្នុងកម្រិតទាប ខណៈដែលឥណទានមិនដំណើរការបន្តកើនឡើង។ ទន្ទឹមនឹងការប្រឈមទាំងនេះ កម្ពុជាក៏បានបន្តធ្វើពិពិធកម្មផលិតផលការនាំចេញ ជំរុញផលិតកម្មក្នុងស្រុកតាមរយៈសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) បង្កើនការកែច្នៃផលិតផលកសិកម្ម និងទាក់ទាញវិនិយោគិនក៏ដូចជាទេសចរអន្តរជាតិ តាមរយៈយុទ្ធនាការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងបង្កើនការតភ្ជាប់ជើងហោះហើរត្រង់ជាមួយបណ្ដាប្រទេសផ្សេងៗបន្ថែមទៀត។ ផ្អែកលើទស្សនវិស័យនេះ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងអាចសម្រេចបានក្នុងអត្រា ៥% ក្នុងឆ្នាំ២០២៦។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ខ្ញុំសូមឯកភាពទៅលើទិសដៅការងារ ដែលបានលើកឡើងដោយថ្នាក់ដឹកនាំរបស់យើងនៅតាមអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ក៏ដូចជាបានរៀបរាប់នៅក្នុងសៀវភៅរបាយការណ៍ឆ្នាំ២០២៥។ ខ្ញុំជឿជាក់ថា ការអនុវត្តបានតាមទិសដៅការងាររបស់យើង ប្រព័ន្ធធនាគារនឹងបន្តរួមចំណែកសម្រេចបានតាមបេសកកម្មចម្បងរបស់ខ្លួនគឺការរក្សាស្ថិរភាពថ្លៃ និងរួមចំណែកគាំទ្រគោល-នយោបាយរបស់រាជរដ្ឋាភិបាល។ លើសពីនេះ ខ្ញុំសូមសង្កត់ធ្ងន់លើទិសដៅចម្បងមួយចំនួន ដូចតទៅ៖

- បន្តអភិវឌ្ឍក្របខណ្ឌនៃការអនុវត្តនយោបាយរូបិយវត្ថុ ជាពិសេសការអភិវឌ្ឍទីផ្សារអន្តរធនាគារ និងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល
- បង្កើនការប្រើប្រាស់បញ្ញាសិប្បនិម្មិត និងបច្ចេកវិទ្យា ដើម្បីបង្កើនប្រសិទ្ធភាពការងារ
- ពង្រឹងការតាមដានសុខភាពប្រព័ន្ធធនាគារ ក៏ដូចជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ពង្រឹងការដាក់ចេញបទប្បញ្ញត្តិសមស្រប ដោយថ្លឹងថ្លែងពីហានិភ័យនិងគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធធនាគារ
- បន្តអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីបង្កើនប្រសិទ្ធភាពទូទាត់ ជាពិសេសការតភ្ជាប់ការទូទាត់ទាំងក្នុងស្រុក និងតំបន់
- បន្តលើកកម្ពស់ការផ្តល់សេវារបស់ធនាគារជាតិនៃកម្ពុជា ជូនដល់ក្រសួង-ស្ថាប័ននានាតាមរយៈប្រព័ន្ធធនាគារអេឡិចត្រូនិក (OBS)
- ជំរុញកិច្ចសហការទាំងក្នុងនិងក្រៅធនាគារជាតិនៃកម្ពុជា ដើម្បីរួមចំណែកពង្រឹងប្រសិទ្ធភាពការងារ និងផ្សព្វផ្សាយគោលនយោបាយសំខាន់ៗរបស់ធនាគារជាតិនៃកម្ពុជា ក៏ដូចជារួមចំណែកក្នុងការប្រឆាំងព័ត៌មានក្លែងក្លាយ ឬមិនត្រឹមត្រូវ និង
- លើកកម្ពស់ចំណេះដឹងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមទម្រង់នានា ជាពិសេស តាមរយៈសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ និងយុទ្ធនាការនៅតាមបណ្តារាជធានី-ខេត្ត។

ខ្ញុំសូមស្នើឱ្យថ្នាក់ដឹកនាំតាមបណ្តាអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាពនិងសាខាធនាគារជាតិនៃកម្ពុជាទាំងអស់ ផ្សព្វផ្សាយបន្តនូវខ្លឹមសារនៃអង្គសន្និបាតរបស់យើងនាពេលនេះឱ្យបានទូលំទូលាយដល់មន្ត្រីបុគ្គលិក ដើម្បីយល់ច្បាស់ពីទិសដៅរួមរបស់យើងទាំងអស់គ្នា។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកយើងនឹងបន្តរួមចំណែកសម្រេចបានសមិទ្ធផលថ្មីៗបន្ថែមទៀត សម្រាប់ធនាគារជាតិនៃកម្ពុជា និងប្រព័ន្ធធនាគារ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិទាំងមូល។

ការងារដែលយើងសម្រេចបាន គឺអាស្រ័យដោយមន្ត្រីបុគ្គលិកគ្រប់លំដាប់ថ្នាក់បានបន្តអភិវឌ្ឍសមត្ថភាព មានសាមគ្គីភាពរឹងមាំ រក្សាការសម្ងាត់វិជ្ជាជីវៈ មានភាពស្មោះត្រង់ និងបំពេញការងារប្រកបដោយ

ការទទួលខុសត្រូវ។ ខ្ញុំសូមស្នើសុំឱ្យមន្ត្រីបុគ្គលិកយើងទាំងអស់បន្តអនុវត្តវប្បធម៌ដ៏ប្រពៃរបស់យើងទាំងនេះ ឱ្យបានខ្ជាប់ខ្ជួនបំផុត ដើម្បីបន្តពង្រឹងនូវគុណតម្លៃស្នូល (Core Value) របស់ធនាគារជាតិនៃកម្ពុជា។ ជាមួយគ្នានេះ មន្ត្រី-បុគ្គលិកយើងត្រូវមានចិត្តទូលាយ ចេះអត់ឱន យោគយល់ និងទទួលយកគំនិតនិងទស្សនៈរបស់អ្នកដទៃមកត្រិះរិះពិចារណា ដើម្បីទទួលបានចំណេះដឹង បទពិសោធ និងការរីកចម្រើន។ ជាការពិតថ្វីបើពេលខ្លះ ទស្សនៈនិងចិត្តមនុស្សអាចខុសគ្នាក្តី យើងក៏ត្រូវរៀនសូត្រពីគ្នាទៅវិញទៅមកនិងប្រកបការងារជាមួយគ្នាដោយសុខុដុមរមនា។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាត សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# សុន្ទរកថាបើក
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ
# ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២

ថ្ងៃពុធ ៩កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦



**សូមគោរព៖**

- **ឯកឧត្តម Christian DesRoches ឯកអគ្គរដ្ឋទូតកាណាដាប្រចាំកម្ពុជា**
- **លោកស្រី Tania Meyer ប្រធានគ្រប់គ្រងធនាគារពិភពលោកនៅកម្ពុជា**
- **ឯកឧត្តម លោកជំទាវ ជាអនុប្រធាន សមាជិក សមាជិកា គ.ស.ហ. ជាទីគោរព!**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំពិតជាមានកិត្តិយស ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.) ឱ្យចូលរួមជាអធិបតី ក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លើកទី២។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ដែលបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយដ៏មានសារៈសំខាន់ នាថ្ងៃនេះ។

ខ្ញុំសូមអរគុណចំពោះ ឯកឧត្តម ហេង បូមករា ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលបានរាយការណ៍អំពីកិច្ចដំណើរការនៃការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី២។ តាមរយៈរបាយការណ៍នេះ គឺបានឆ្លុះបញ្ចាំងឱ្យឃើញពីកិច្ចប្រឹងប្រែងរបស់ប្រទេសកម្ពុជាក្នុងការធានាការអនុលោមតាមស្តង់ដារអន្តរជាតិលើការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**គណៈអធីបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាទីមេត្រី!**

ក្នុងនាមជាសមាជិកនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) ប្រទេសកម្ពុជាត្រូវមានកាតព្វកិច្ចអនុវត្តស្តង់ដារបស់ក្រុមការងារហិរញ្ញវត្ថុ (FATF) និងចូលរួមជាមួយបណ្តាប្រទេសនានាក្នុងការ

ប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងបទល្មើសនានាដើម្បីធានាឱ្យបាននូវសុចរិតភាពនៃប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ។ ក្នុងបរិបទនេះ រាជរដ្ឋាភិបាលកម្ពុជាបានបន្តយកចិត្តទុកដាក់លើការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដោយបានដាក់ចេញនូវវិធានការចាំបាច់នានាក្នុងការពង្រឹងក្របខណ្ឌគតិយុត្ត និងការបង្កើនប្រសិទ្ធភាពស្ថាប័ននិងកិច្ចសហប្រតិបត្តិការក្នុងស្រុកនិងអន្តរជាតិ ទាំងកម្រិតនយោបាយ និងកម្រិតប្រតិបត្តិការ សំដៅការពារសុចរិតភាព ស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ និងបង្កើនជំនឿទុកចិត្តរបស់វិនិយោគិនក្នុងស្រុក និងបរទេស ដើម្បីជំរុញកំណើនសេដ្ឋកិច្ចរបស់កម្ពុជាប្រកបដោយចីរភាព។ ការយកចិត្តទុកដាក់នេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការកំណត់ការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាការងារអាទិភាព ដូចមានក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ២០២៥-២០៣០ ជាដើម។




ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានកន្លងមក ការកើនឡើងនៃបទល្មើសផ្សេងៗ ដូចជាបទល្មើសគ្រឿងញៀន ការជួញដូរមនុស្ស ការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាដែលមានភាពស្មុគស្មាញ និងមានលក្ខណៈឆ្លងដែន បាននិងកំពុងគំរាមកំហែងដល់ស្ថិរភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ក៏ដូចជាក្នុងតំបន់ និងសកលលោក។ ជាមួយគ្នានេះ ការរីកចម្រើននៃប្រព័ន្ធបច្ចេកវិទ្យា និងទ្រព្យនិម្មិត (Virtual Assets) ក៏បានផ្តល់ឱកាសដល់ក្រុមឧក្រិដ្ឋជនប្រើប្រាស់ជាមធ្យោបាយ ក្នុងការបំប្លែងនិងបិទបាំងផលនៃបទល្មើសដែលជាសកម្មភាពនៃការសម្អាតប្រាក់ផងដែរ។ ក្នុងស្ថានភាពនេះ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) ដឹកនាំដោយ **សម្តេចមហាបវរធិបតី** នាយករដ្ឋមន្ត្រី ដែលបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់របស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើសនេះ។ ក្រោយពីការបង្កើតគណៈកម្មការនេះមក បទល្មើសឆបោកជាច្រើនត្រូវបានបង្ក្រាប ហើយជនល្មើសជាច្រើននាក់ត្រូវបានឃាត់ខ្លួន និងផ្តន្ទាទោស ជាបន្តបន្ទាប់។

ស្របគ្នានឹងកិច្ចខិតខំប្រឹងប្រែងទាំងនេះ ដើម្បីជំរុញឱ្យការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឱ្យកាន់តែមានប្រសិទ្ធភាព និងសម្រេចបានគោលដៅខ្ពស់ ប្រទេសកម្ពុជាចាំបាច់ត្រូវយល់ដឹងឱ្យកាន់តែច្បាស់ និងទូលំទូលាយអំពីហានិភ័យ ដែលកំពុងកើតមាន និងដាក់ចេញនូវវិធានការចាំបាច់ និងសមស្រប

នានាដើម្បីកាត់បន្ថយ និងគ្រប់គ្រងហានិភ័យទាំងនេះ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានសម្រេចឱ្យមានការវាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី២ នេះឡើង។ ចំពោះកម្រិតហានិភ័យដែលយើងទទួលបាននេះ គឺបានបង្ហាញពីលទ្ធផលការងាររបស់ក្រសួងស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន ដែលបានខិតខំប្រឹងប្រែងអនុវត្តនាពេលកន្លងមក ក៏ដូចជាការងារដែលគ្រប់ភាគីពាក់ព័ន្ធទាំងអស់ចាំបាច់ត្រូវសហការគ្នា បន្តអនុវត្តឱ្យបានពេញលេញនិងមានប្រសិទ្ធភាព។ បន្ថែមពីនេះ ការយល់ដឹងរបស់ភាគីពាក់ព័ន្ធទាំងអស់អំពីលទ្ធផលនៃការវាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី២ នេះ គឺមានភាពចាំបាច់។




ក្នុងទិសដៅនេះ ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយនាថ្ងៃនេះ ពិតជាមានសារៈសំខាន់ សម្រាប់គ្រប់ភាគីពាក់ព័ន្ធក្នុងការស្វែងយល់ពីកម្រិតហានិភ័យនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដើម្បីចាត់វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលា។ ជាមួយគ្នានេះ យើងនឹងបន្តផ្សព្វផ្សាយលទ្ធផលរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី២នេះ ទៅគ្រប់ភាគីពាក់ព័ន្ធ ជាបន្តបន្ទាប់។

**គណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាទីមេត្រី!**

ជាថ្មីម្តងទៀត ខ្ញុំសូមជម្រាបអង្គសិក្ខាសាលាជ្រាបថា ការវាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី២នេះ នឹងប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការរៀបចំយុទ្ធសាស្ត្រថ្នាក់ជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា និងជាឯកសារសម្រាប់ការត្រៀមខ្លួនទទួលការវាយតម្លៃអញ្ញមញ្ញនាពេលខាងមុខ ក្នុងលក្ខណៈបុរេសកម្ម និងមានការទទួលខុសត្រូវ។ ដូចនេះខ្ញុំសូមស្នើឱ្យអង្គសិក្ខាសាលាទាំងមូល មេត្តាត្រងត្រាប់ស្តាប់

ការធ្វើបទបង្ហាញរបស់វាគ្មិនរបស់យើងដោយយកចិត្តទុកដាក់ អំពីលទ្ធផលដែលមាននៅក្នុងរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម លើកទី២។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាម ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន គ.ស.ហ. និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចមហាបវរធិបតី** នាយករដ្ឋមន្ត្រី ដែលតែងតែផ្តល់ការគាំទ្រយ៉ាងពេញទំហឹង និងជាប្រចាំ លើការងារវាយតម្លៃហានិភ័យថ្នាក់ជាតិនេះរហូតទទួលបានជោគជ័យ។ ខ្ញុំក៏សូមថ្លែងអំណរគុណ ចំពោះប្រទេសកាណាដានិងធនាគារពិភពលោកដែលបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសដល់ការរៀបចំការវាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី២ នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណ អនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (អ.វ.ហ.) ក្រុមការងារចម្រុះ ក្រុមការងារបច្ចេកទេសទាំងអស់តំណាងឱ្យក្រសួងស្ថាប័នពាក់ព័ន្ធ និងគ្រប់ភាគីពាក់ព័ន្ធដែលបានលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលា និងផ្តល់កិច្ចសហការយ៉ាងសកម្មនៅក្នុងដំណើរការវាយតម្លៃហានិភ័យថ្នាក់ជាតិនេះ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយដ៏មានសារៈសំខាន់នេះ និងសូមជូនពរឱ្យសិក្ខាសាលាផ្សព្វផ្សាយនេះប្រព្រឹត្តទៅដោយពិលាស ព្រមទាំងទទួលបាននូវកិច្ចសហការល្អពីភាគីពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឱ្យបន្តសម្រេចបានជោគជ័យនាពេលខាងមុខ។ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើកសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លើកទី២ ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**

# សុន្ទរកថា
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធអគារសិក្សា ១ខ្នង ៥បន្ទប់ និងសមិទ្ធផលនានា
# នៅសាលាបឋមសិក្សាត្រពាំងផ្អៀក ស្ថិតក្នុងឃុំសាលាវិស័យ
# ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ

ថ្ងៃសៅរ៍ ៤រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ខេត្តកំពង់ធំ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៦



**សូមគោរព**

- **ឯកឧត្តម ថា យ៉ាវ តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ**
- **លោក គង់ សំអាត អភិបាលនៃគណៈអភិបាលស្រុកប្រាសាទបល្ល័ង្គ**
- **គណៈអធិបតី លោក-លោកស្រី នាយក-នាយករង លោកគ្រូ-អ្នកគ្រូ**
- **អ៊ំ ពូ មីង ដែលជាអាណាព្យាបាលសិស្ស និងក្មួយៗ សិស្សានុសិស្សទាំងអស់ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយជាអនេក ដែលបានចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារសិក្សា ១ខ្នង មាន ៥បន្ទប់ និងសមិទ្ធផលនានានៃសាលាបឋមសិក្សាត្រពាំងផ្អៀក ជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ-អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងបងប្អូនប្រជាពលរដ្ឋ នៅឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ នាពេលនេះ។

ខ្ញុំសូមអរគុណ លោក គង់ សំអាត ដែលបានធ្វើរបាយការណ៍យ៉ាងក្បោះក្បាយ។ តាមរយៈរបាយការណ៍នេះ យើងឃើញថា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងអាណត្តិកន្លងទៅ និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៧នេះ តែងតែចាត់ទុកការសិក្សាអប់រំជាអាទិភាពមួយដ៏សំខាន់ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានស្តារ និងពង្រឹងវិស័យអប់រំជាបន្តបន្ទាប់ តាមរយៈការពង្រឹងទាំងគុណភាពសិក្សា និងការកសាងអគារសិក្សានៅទូទាំងប្រទេស។ ដោយឡែក នៅខេត្តកំពង់ធំ **ឯកឧត្តម ជា ចាន់តូ** ទេសាភិបាលកិត្តិយស ធនាគារជាតិនៃកម្ពុជា និងជាអតីតតំណាងរាស្ត្រមណ្ឌល

ខេត្តកំពង់ធំ តែងតែខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តកសាងសមិទ្ធផលជាច្រើននៅក្នុងខេត្តកំពង់ធំ ជាពិសេសបានបន្សល់ទុកនូវអគារសិក្សានិងសមិទ្ធផលនានាជាច្រើនទាំងនៅបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ មន្ទីរអប់រំ យុវជន និងកីឡា លោកនាយក លោកគ្រូ អ្នកគ្រូ និងដៃគូអភិវឌ្ឍនានា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អ និងរួមសាមគ្គីគ្នាកសាងអគារសិក្សានេះឡើង សម្រាប់បម្រើវិស័យអប់រំ និងសម្រួលដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់គ្នា ក្នុងដំណើរឆ្ពោះទៅសម្រេចនូវគោលដៅអភិវឌ្ឍន៍ធនធានមនុស្សកម្ពុជា។



**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗទាំងអស់ ជាទីមេត្រី!**

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចមហាបវរធិបតី** នាយករដ្ឋមន្ត្រី រាជរដ្ឋាភិបាលនីតិកាលថ្មីបាននិងកំពុងធ្វើដំណើរទៅមុខយ៉ាងស្វាហាប់ និងបន្តយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើវិស័យសំខាន់ៗនានាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសការអភិវឌ្ឍមូលធនមនុស្ស ដែលជាអាទិភាព ក្នុងយុទ្ធសាស្ត្របញ្ចកោណសម្រាប់ការអនុវត្តនៅគ្រប់ដំណាក់កាល។ សម្តេចបវរធិបតី នាយករដ្ឋមន្ត្រី បានផ្តល់អនុសាសន៍គន្លឹះ ៤ចំណុច សំដៅលើកកម្ពស់គុណភាពអប់រំ ដោយផ្តោតសំខាន់លើការពង្រឹងគុណភាពសាលារៀនរដ្ឋ រួមមាន៖ ទី១. ការពង្រឹងអភិបាលកិច្ច ទី២. ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការ ក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស ទី៣. ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស និងទី៤. ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក "ភាពជាដៃគូរដ្ឋ និងសហគមន៍ ដើម្បីការអប់រំ"។

សាលាបឋមសិក្សាត្រពាំងផ្អៀក គឺជាថ្នាលសិក្សាគ្រឹះមួយដ៏សំខាន់ ដែលបានចូលរួមចំណែកអភិវឌ្ឍធនធានមនុស្សកម្ពុជា តាមរយៈការពង្រឹងការបណ្តុះបណ្តាលដល់ក្មួយៗសិស្សានុសិស្ស ដែលជាទំពាំងស្នងឫស្សីជំនាន់ក្រោយប្រកបដោយគុណភាព។ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិក

ធនាគារជាតិនៃកម្ពុជាទាំងអស់ ពិតជាមានចិត្តសប្បាយរីករាយដែលបានចូលរួមវិភាគទាន ក្នុងដំណើរការពង្រឹងវិស័យអប់រំនៅកម្ពុជា ដែលជាបុព្វហេតុកសាងធនធានមនុស្សប្រកបដោយចំណេះដឹងគ្រប់គ្រាន់ ដែលអាចចូលរួមចំណែក ក្នុងកិច្ចការអភិវឌ្ឍសង្គមជាតិ ស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល។ ការពង្រឹងការបណ្តុះបណ្តាលដល់ក្មួយៗសិស្សានុសិស្ស ដែលជាកម្លាំងបន្តវេន និងធនធានមនុស្សប្រកបដោយសក្តានុពល នឹងនាំឱ្យប្រទេសជាតិកាន់តែរីកចម្រើន និងមានការអភិវឌ្ឍជាលំដាប់។ ក្រៅពីអគារសិក្សា ១ខ្នង មាន ៥បន្ទប់នេះ សមិទ្ធផលនានាដូចជាក្លោងទ្វារសាលា ការជួសជុលអគារសិក្សា ការសាងសង់ផ្ទះបាយ និងការចាក់ដីបន្ថែម ដើម្បីផ្តល់ជូននូវទីតាំងកន្លែងសិក្សា និងបរិស្ថាន ដែលល្អប្រសើរ និងកាន់តែទាក់ទាញក្មួយៗឱ្យខិតខំសិក្សារៀនសូត្របានកាន់តែខ្លាំងជាងមុនពីមួយថ្ងៃទៅមួយថ្ងៃ។

ទន្ទឹមនឹងនេះ ក្មួយៗត្រូវយកចិត្តទុកដាក់ខិតខំរៀនសូត្រឱ្យបានខ្លាំងក្លា ដូចប្រសាសន៍ **សម្តេចធិបតី** នាយករដ្ឋមន្ត្រី តែងតែលើកឡើងថា "រៀនឱ្យចេះ រៀនឱ្យមានជំនាញ និងរៀនឱ្យមានការងារធ្វើ"។ ដើម្បីរៀនឱ្យចេះ មីងសូមលើកយកនូវអង្គ៤ (សុ ចិ ពុ លិ ឬ ស្តាប់ គិត សួរ កត់ត្រា)។ ក្មួយត្រូវត្រងត្រាប់ស្តាប់លោកគ្រូ-អ្នកគ្រូបង្ហាត់បង្រៀន ហើយគិតសួរខ្លួនឯងសិន តើយល់មេរៀនឬទេ? ប្រសិនមិនយល់ត្រូវសួរលោកគ្រូ-អ្នកគ្រូនូវចំនុចដែលក្មួយៗមិនយល់ ហើយដើម្បីចងចាំ ក្មួយៗត្រូវកត់ត្រាទុកក្នុងសៀវភៅ ដែលងាយស្រួលរំលឹកនៅពេលក្រោយ។

ក្មួយៗទាំងអស់ចូរចាំថា ជោគជ័យក្នុងការសិក្សារបស់ក្មួយៗ គឺជាមោទនភាពរបស់មាតាបិតា លោកគ្រូ-អ្នកគ្រូ រាជរដ្ឋាភិបាល និងសប្បុរសជនដែលជាអ្នកឧបត្ថម្ភយើង។ ហេតុនេះ សូមក្មួយៗខិតខំរៀនសូត្រឱ្យក្លាយជាសិស្សឆ្នើម និងសិស្សពូកែ ឱ្យសមទៅនឹងពាក្យស្លោក "ទំពាំងស្នងឫស្សី" របស់ជាតិយើង។

ខ្ញុំក៏សូមជម្រាបផងដែរថា កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៦ ក្រោមគំនិតផ្តួចផ្តើមរបស់**លោកជំទាវ ខៀវ ស៊ីណា ជា ចាន់តូ** (ម្តាយរបស់ខ្ញុំ) យើងបានរៀបចំពិធីបញ្ចុះបឋមសិលាសាងសង់អគារវិទ្យាល័យ ជា ចាន់តូ។ វិទ្យាល័យ ជា ចាន់តូ ត្រូវបានបង្កើតឡើង ដើម្បីជាការចងចាំចំពោះ **ឯកឧត្តម ជា ចាន់តូ** (ឪពុករបស់ខ្ញុំ) ក្នុងគោលបំណងផ្តល់នូវការអប់រំបណ្តុះបណ្តាលដែលមានគុណភាព និងស្តង់ដាខ្ពស់ពីថ្នាក់ទី១០-ទី១២ សម្រាប់ក្មួយៗសិស្សានុសិស្សក្នុងខេត្តកំពង់ធំ ដែលមានការតាំងចិត្តខ្ពស់ និងរៀនពូកែ ដោយវិទ្យាល័យនឹងផ្តល់





អាហារូបករណ៍លើថ្លៃសិក្សា ហើយចំពោះក្មួយៗ ដែលមកពីកន្លែងឆ្ងាយ និងមានជីវភាពខ្វះខាត វិទ្យាល័យនឹងផ្តល់កន្លែងស្នាក់នៅ និងការហូបចុកបន្ថែមទៀត។

ខ្ញុំក៏សូមឆ្លៀតយកឱកាសនេះ រំលឹកដល់មាតាបិតាគ្រប់រូបឱ្យយកចិត្តទុកដាក់បញ្ជូនកូនឱ្យបានចូលរៀនគ្រប់ៗគ្នា ព្រោះនេះមិនត្រឹមតែជាកាតព្វកិច្ចដ៏សំខាន់របស់មាតាបិតាគ្រប់រូបប៉ុណ្ណោះទេ តែក៏ជាការសន្សំប្រាក់ឱ្យកូន និងជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការជួយស្រោចស្រង់ជីវភាពឱ្យរួចផុតពីភាពក្រីក្រផងដែរ ដូចពាក្យស្លោកមួយបានពោលថា៖ "ការសិក្សាគឺជាស្ពានឆ្ពោះទៅអនាគត ចង់មានថ្ងៃស្អែកទាល់តែរៀបចំពីថ្ងៃនេះ"។ លើសពីនេះ ការបញ្ជូនកូនមករៀន ក៏ជាការរួមចំណែកកសាងនិងអភិវឌ្ឍសង្គមជាតិយើងសម្រាប់រយៈពេលវែង ដោយសារក្មួយៗដែលកំពុងសិក្សានាពេលនេះ នឹងក្លាយជាសសរទ្រូងដ៏រឹងមាំប្រកបដោយគុណភាពនៅក្នុងវិស័យនានា ហើយក្មួយៗក៏អាចក្លាយជាថ្នាក់ដឹកនាំ នាពេលអនាគតទៀតផង។ ដូច្នេះ ខ្ញុំសូមលើកទឹកចិត្តឱ្យអ៊ំ ពូ មីង បងប្អូន ជាអាណាព្យាបាល បញ្ជូនកូនមកសាលា ជួយលើកទឹកចិត្តកូន និងបង្កលក្ខណៈឱ្យកូនៗបានបន្តការសិក្សាទាំងកូនប្រុស និងកូនស្រី។ ជាពិសេស ការបញ្ជូនកុមារីមកសាលារៀន ដើម្បីទទួលបានការសិក្សាអប់រំឱ្យបានពេញលេញពិតជាមានសារៈសំខាន់ ដោយសារស្ត្រីមិនត្រឹមតែមានតួនាទីក្នុងគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកម្លាំងសំខាន់ក្នុងការចូលរួមអភិវឌ្ឍសង្គមជាតិ និងលើកមុខមាត់របស់កម្ពុជាលើឆាកអន្តរជាតិផងដែរ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្មួយៗទាំងអស់ ជាទីមេត្រី!**

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ មាតាបិតា-អាណាព្យាបាល ប្រជាពលរដ្ឋក្នុងឃុំសាលាវិស័យ និងក្មួយៗទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធអគារសិក្សា ១ខ្នង ៥បន្ទប់ និងសមិទ្ធផលនានា ក្នុងសាលាបឋមសិក្សាត្រពាំងផ្អៀក នាពេលនេះ និងសូមអរគុណដល់ក្រុមការងារធនាគារជាតិនៃកម្ពុជា អាជ្ញាធរមូលដ្ឋាន និងគណៈគ្រប់គ្រងសាលា ដែលបានចូលរួមសហការរៀបចំកម្មវិធីនេះឡើង។

ខ្ញុំក៏សូមអំពាវនាវឱ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស អាជ្ញាធរមានសមត្ថកិច្ច មាតាបិតា និងអាណាព្យាបាលសិស្សទាំងអស់ សូមមេត្តាជួយថែរក្សាអគារសិក្សានេះ ឱ្យបានគង់វង្សជាប្រយោជន៍ ដើម្បីប្រើប្រាស់សមិទ្ធផលទាំងនេះឱ្យបានយូរអង្វែងសម្រាប់ជាថ្នាល ដើម្បីអប់រំបណ្តុះបណ្តាលដល់កូនចៅជំនាន់ក្រោយរបស់យើងតរៀងទៅ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាយក នាយករង លោកគ្រូ អ្នកគ្រូ អ៊ំ ពូ មីង និងក្មួយៗទាំងអស់ សូមសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារសិក្សា ១ខ្នង ៥បន្ទប់ នៅសាលាបឋមសិក្សាត្រពាំងផ្អៀក ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**

# សុន្ទរកថា
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ក្នុងពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយូអរកូដរវាង ព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសិង្ហបុរី
# (ដំណាក់កាលទី២៖ សិង្ហបុរីស្កេនខេអេចយូអរកូដនៅក្នុងប្រទេសកម្ពុជា)

**Remarks by**

**H.E. Dr. Chea Serey, Governor of the National Bank of Cambodia**

**at the Official Launch of Cross-Border QR Code Payment between**

**Cambodia and Singapore (Phase 2: Singapore scans KHQR)**

Phnom Penh, 30th March 2026




**- Excellencies, Distinguished Guests, Ladies and Gentlemen!**

Good morning and a very warm welcome to everyone!

It is an honor to join you today for the official launch of Phase 2 of the cross-border QR payment linkage between Cambodia and Singapore. This milestone builds on the successful launch of Phase 1 at the Singapore FinTech Festival on 12 November 2025, which enabled Cambodian users to make convenient and secure payments in Singapore through Bakong and participating mobile banking applications. Today, we take the next important step by enabling Singaporean travelers to scan KHQR codes and make seamless payments across Cambodia.

This achievement reflects the strong commitment and close collaboration of our public and private sector partners, especially Acleda Bank Plc, Phillip Bank Plc, and Liquid Group. Their partnership demonstrates a shared vision to modernize cross-border payments, promote the use of local currencies, and advance financial inclusion through practical innovation.

This progress is built on the success of Bakong, Cambodia's DLT-based payment infrastructure, launched in 2020 to connect the country's financial system on a single platform. Bakong now links 69 financial institutions and serves as a strong foundation for expanding payment connectivity beyond our borders. In addition to Singapore, Cambodia has already established cross-border payment linkages with Thailand, Vietnam, Laos, Malaysia, Korea,




Japan, and China through Alipay and UnionPay, while India and the Philippines are expected to join in the near future.

The growing use of these services shows clear demand for fast, secure, and seamless cross-border payments. By the end of 2025, Bakong had facilitated inbound cross-border payments totaling approximately 64.5 billion riels, or about 16.13 million U.S. dollars, and outbound payments of around 15.9 million U.S. dollars.

With today's launch, Singaporean travelers can now use their mobile banking applications to scan KHQR codes at around 4.5 million merchants across Cambodia. This will make travel more convenient, support tourism and retail activity, reduce reliance on cash, lower






transaction costs for small and medium-sized enterprises, and encourage greater participation in the formal financial system.

**Excellencies, Distinguished Guests, Ladies and Gentlemen,**

This initiative is more than a pa yment solution. It is also a bridge between the economies and people of Cambodia and Singapore, and a meaningful step toward deeper regional financial integration within ASEAN. It reflects our continued commitment to building a digital financial ecosystem that is inclusive, secure, and resilient.

I would like to thank all partners who have contributed to this important milestone. Let us continue working together to advance payment interoperability and strengthen regional connectivity for the benefit of our businesses, our citizens, and future generations.

**Thank you!**

# សុន្ទរកថា
# ឯកឧត្តម រ័ត្ន សុវណ្ណានរ: ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងកម្មវិធីបើកវគ្គបណ្តុះបណ្តាលដល់គ្រូបង្គោលនៃគម្រោង
# "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍"

ថ្ងៃពុធ ១៥រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦



- **លោកជំទាវ ឱិត នីតា អនុប្រធានក្រុមប្រឹក្សាភិបាល សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា**
- **សមាជិក សមាជិកា ក្រុមការងារដឹកនាំការអនុវត្ត ថ្នាក់កណ្តាល**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូន ជាក្រុមគ្រូបង្គោលថ្នាក់ឃុំ សមាជិក-សមាជិកា នៃអង្គពិធីជាទីមេត្រី!**

តាងនាម **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងក្នុងនាមរូបខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដែលបានចូលរួម និងថ្លែងសុន្ទរកថាបើកវគ្គបណ្តុះបណ្តាលដល់គ្រូបង្គោល (TOT) នៃគម្រោងការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍ស្តីពី "ចំណេះដឹងផ្នែកហិរញ្ញវត្ថុ សិទ្ធិ និងកិច្ចការពារអតិថិជន" នាថ្ងៃនេះ។ វគ្គបណ្តុះបណ្តាលនេះពិតជាមានសារៈសំខាន់ និងមានអត្ថន័យយ៉ាងសំខាន់ក្នុងបរិបទបច្ចុប្បន្ន ជាពិសេសនៅពេលដែលវិស័យធនាគារ និងហិរញ្ញវត្ថុ កំពុងបន្តដើរតួនាទីយ៉ាងសកម្ម ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់ជូននូវផលិតផល និងសេវាហិរញ្ញវត្ថុយ៉ាងសម្បូរបែបសម្រាប់ការប្រកបអាជីវកម្ម និងសកម្មភាពរស់នៅប្រចាំថ្ងៃផ្សេងទៀត។ ទន្ទឹមនេះ ការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុតាមរយៈគ្រូបង្គោល (TOT) ជាការរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងសមត្ថភាពសហគមន៍ ឱ្យប្រជាពលរដ្ឋអាចប្រើប្រាស់សេវាហិរញ្ញវត្ថុដោយភាពវៃឆ្លាត កាត់បន្ថយហានិភ័យ និងការឆបោកផ្នែកហិរញ្ញវត្ថុ ជាពិសេសការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិ និងកិច្ចការពារអតិថិជន។ ជាមួយគ្នានេះ គ្រូបង្គោលទាំងអស់ បាននិងកំពុងក្លាយជាកម្លាំងចលករដ៏សំខាន់ក្នុងការផ្សព្វផ្សាយ និងបង្ហិតចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅដល់សហគមន៍ឱ្យកាន់តែកៀក ដើម្បីរួមចំណែកកសាងភាពសុខដុមរមនាក្នុងសហគមន៍ និងលើសពីនេះ គឺដើម្បីចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។

ក្នុងឱកាសនោះ ខ្ញុំសូមកោតសរសើរចំពោះការគិតគូររបស់គណៈកម្មាធិការដឹកនាំថ្នាក់កណ្តាលនៃគម្រោង រួមមាន ធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិល ធីឌី និងអង្គការ Ceries+SPTF ដែលបានពង្រីកវិសាលភាពគម្រោងទៅកាន់ឃុំគោលដៅថ្មី ចំនួន ៥ និងមានគ្រូបង្គោលសហគមន៍ថ្មីចំនួន ៦៧ រូប ក្នុងឆ្នាំ២០២៦នេះ និងជាពិសេសបានរៀបចំវគ្គបណ្តុះបណ្តាលដ៏ចាំបាច់នេះឡើង ដើម្បីធានាថាគ្រូបង្គោលទាំងអស់មានចំណេះដឹង និងជំនាញគ្រប់គ្រាន់ សម្រាប់អនុវត្តភារកិច្ចការងារប្រចាំថ្ងៃឱ្យកាន់តែមានប្រសិទ្ធភាព និងឈានទៅរកកម្រិតខ្ពស់ជាងមុនស្របតាមបរិបទ និងតម្រូវការពិតប្រាកដរបស់សហគមន៍។ ជាងនេះទៅទៀត វគ្គបណ្តុះបណ្តាលនេះ បានផ្តល់ឱកាសដល់គ្រូបង្គោលទាំងអស់ ក្នុងការធ្វើការពិភាក្សា និងផ្លាស់ប្តូរយោបល់អំពីបញ្ហាប្រឈម និងដំណោះស្រាយផ្សេងៗ ព្រមទាំងពង្រីក និងពង្រឹងទំនាក់ទំនងគ្នាទៅវិញទៅមក ដើម្បីជំរុញសកម្មភាពជាក់ស្តែង ក្នុងការលើកកម្ពស់សមត្ថភាព ផ្នែកហិរញ្ញវត្ថុនៅតាមមូលដ្ឋានរៀងៗខ្លួន។






**ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជា ក្រុមគ្រូបង្គោលថ្នាក់ឃុំ សមាជិក-សមាជិកនៃអង្គពិធីជាទីមេត្រី!**

ក្នុងរយៈពេលជាងមួយទស្សវត្សនេះ វិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា មានការរីកចម្រើនយ៉ាងឆាប់រហ័ស ហើយបានចូលរួមគាំទ្រកំណើនសេដ្ឋកិច្ច និងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់ប្រជាជនទាំងនៅទីប្រជុំជន និងនៅតាមទីជនបទ។ ទោះយ៉ាងនេះក្តី បញ្ហាកម្ចីខុសច្បាប់បានរីកសុះសាយ រួមមានការក្លែងបន្លំ និងការឆបោកផ្នែកហិរញ្ញវត្ថុ ដែលទាំងនេះអាចនាំឱ្យមានការភាន់ច្រឡំជាមួយការប្រើប្រាស់សេវាធនាគារ និងហិរញ្ញវត្ថុផ្លូវការ នាំមកនូវការរំខានក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋតាមមូលដ្ឋាន។

ជាមួយគ្នានេះ កម្ចីខុសច្បាប់បាន និងកំពុងរាតត្បាតនៅកម្ពុជា ដែលនាំឱ្យប្រជាពលរដ្ឋរងការជំពាក់បំណុលវ័ណ្ឌកដោះខ្លួនមិនរួច នាំឱ្យកើតទៅជាវិបត្តិផ្លូវចិត្ត។ ក្នុងន័យនេះ ប្រជាពលរដ្ឋអាចប្រឈមមុខនឹងការគំរាមកំហែង គៀបសង្កត់ គ្រោះថ្នាក់ ឬរូបភាពផ្សេងៗ ដើម្បីបង្ខំឱ្យសងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យខុសគោលការណ៍។ ហើយទ្រព្យសម្បត្តិអាចត្រូវបានរឹបអូសដោយពុំឆ្លងកាត់ការសម្រេចពីតុលាការជាដើម។

បន្ថែមពីនេះ ក៏មានករណីឆបោក និងការក្លែងបន្លំ (Scam និង Fraud) ជាពិសេសតាមប្រព័ន្ធអនឡាញ កើតឡើងកាន់តែច្រើនផងដែរ។ ជនខិលខូចតែងប្រើប្រាស់បណ្ដាញអ៊ីនធឺណិត ដូចជា អ៊ីមែល តេឡេក្រាម ឬ កម្មវិធីទំនាក់ទំនងផ្សេងៗ ដើម្បីបោកបញ្ឆោតឱ្យប្រជាពលរដ្ឋផ្ទេរប្រាក់ ឬផ្ដល់ព័ត៌មានផ្ទាល់ខ្លួន។ សកម្មភាពទាំងនេះអាចបង្កការខាតបង់ផ្នែកហិរញ្ញវត្ថុ បង្កការភ័ន្តច្រឡំ និងប៉ះពាល់ដល់ទំនុកចិត្តរបស់សាធារណជនលើប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុផ្លូវការ។

ថ្មីនេះៗ ករណីផ្សព្វផ្សាយព័ត៌មានបំផ្លើស ឬព័ត៌មានមិនពិត តាមបណ្ដាញសង្គម និងមធ្យោបាយផ្សេងៗ បង្កការភ័ន្តច្រឡំ និងប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ព្រមទាំងទំនុកចិត្តលើគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ការផ្សព្វផ្សាយព័ត៌មានមិនត្រឹមត្រូវបែបនេះ បានបង្កភាពភ័យខ្លាចក្នុងសង្គម និងធ្វើឱ្យប្រជាពលរដ្ឋមានការយល់ច្រឡំចំពោះប្រព័ន្ធហិរញ្ញវត្ថុផ្លូវការ។

ខ្ញុំសូមយកឱកាសនេះគូសបញ្ជាក់ផងដែរថា យុទ្ធសាស្ត្រជាតិ ស្ដីពី បរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ ក៏បានបង្ហាញថា ឧបសគ្គចម្បងនៃបរិយាបន្នហិរញ្ញវត្ថុ គឺការយល់ដឹង និងចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅកម្ពុជាមានកម្រិតទាប។ ហេតុដូច្នេះ ការយល់ដឹងអំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុគឺជាកត្តាគន្លឹះក្នុងការស្វែងយល់អំពីព័ត៌មានហិរញ្ញវត្ថុ ការទាញយកអត្ថប្រយោជន៍និងការប្រើប្រាស់សេវាហិរញ្ញវត្ថុ សម្រាប់បង្កើនសុខុមាលភាពសេដ្ឋកិច្ចគ្រួសារ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជា ក្រុមគ្រូបង្គោលថ្នាក់ឃុំ សមាជិក-សមាជិកនៃអង្គពិធីជាទីមេត្រី!**

ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យលើប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអនុវត្តវិធានការជាច្រើន ដើម្បីទប់ស្កាត់ និងលុបបំបាត់កម្មវិធីខុសច្បាប់ តាមរយៈការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុជូនដល់សាធារណជនទូទៅ និងក្រុមគោលដៅនានា ក្នុងគោលបំណងជំរុញឱ្យប្រជាពលរដ្ឋ ប្រើប្រាស់ផលិតផល និងសេវាហិរញ្ញវត្ថុផ្លូវការ ព្រមទាំងពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ សមាគមក្នុងវិស័យ និងដៃគូអភិវឌ្ឍន៍។

ជាក់ស្ដែង សកម្មភាពអាទិភាពមួយចំនួនដែល ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអនុវត្តរួមមាន៖ ១/- រៀបចំសិក្ខាសាលា ស្ដីពី "ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន" ក្នុងគោលបំណងផ្សព្វផ្សាយពីចំណេះដឹងផ្នែកហិរញ្ញវត្ថុ ជាពិសេសបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ និងកិច្ចការពារអតិថិជនជូនដល់អាជ្ញាធរពាក់ព័ន្ធនៅតាមមូលដ្ឋាន។ ទន្ទឹមនេះ សិក្ខាសាលាប្រមូលធាតុចូល ស្ដីពី "ការប្រើប្រាស់ផលិតផល និងសេវាហិរញ្ញវត្ថុ" ត្រូវបានរៀបចំឡើង ដើម្បីស្វែងយល់ពីស្ថានភាពជាក់ស្ដែងរបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ និងកម្មវិធីខុសច្បាប់ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងអាជ្ញាធរពាក់ព័ន្ធអំពីបញ្ហានៃកម្មវិធីខុសច្បាប់។ ២/- កិច្ចសហការជាមួយក្រសួងអប់រំ យុវជន

និងកីឡា ក្នុងការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ ៣/- កិច្ចសហការជាមួយក្រសួងកិច្ចការនារី ក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនស្ត្រី ៤/- កិច្ចសហការជាមួយអង្គការ Good Return ក្នុងការលើកកម្ពស់ចំណេះដឹងក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ និង ៥/- កិច្ចសហការរៀបចំកម្មវិធី "នវានុវត្តបរិយាបន្នហិរញ្ញវត្ថុ" និង "ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថល" ជាមួយក្រុមហ៊ុន គ្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ក្នុងគោលបំណងស្វែងរកគំនិតច្នៃប្រឌិតតាមរយៈការប្រកួតប្រជែងពីបណ្ដាសិស្ស-និស្សិតមកពីសាកលវិទ្យាល័យនានា។

បន្ថែមពីនេះ សេចក្ដីថ្លែងការណ៍រួមរវាង ក្រសួងមហាផ្ទៃ ធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលត្រូវបានចេញផ្សាយកាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥ ស្ដីពីការចាត់វិធានការចំពោះសកម្មភាពផ្ដល់កម្ចីខុសច្បាប់ និងការទទួលយកអត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ ប័ណ្ណសមធម៌ និងប័ណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គម ជាវត្ថុធានាលើកម្ចី ក៏ជាវិធានការសំខាន់មួយក្នុងការការពារប្រជាពលរដ្ឋពីហានិភ័យដែលបណ្ដាលមកពីកម្ចីខុសច្បាប់។ បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីអន្តរាគមន៍ និងចាត់វិធានការផ្លូវច្បាប់ចំពោះក្រុមផ្ដល់កម្ចីខុសច្បាប់ ដែលបានប្រើប្រាស់កម្មវិធីទូរសព្ទ ជាដើម។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តពង្រឹងយន្តការគ្រប់គ្រង និងដោះស្រាយបណ្ដឹងអតិថិជន តាមរយៈការសម្របសម្រួលដោះស្រាយបណ្ដឹងរបស់អតិថិជន ដែលប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ តាមរយៈលេខទូរសព្ទហត់ឡាញរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីផ្ដល់លទ្ធភាពបន្ថែមដល់អ្នកប្រើប្រាស់អាចដាក់ពាក្យបណ្ដឹង ស្នើសុំការអន្តរាគមន៍ឬសាកសួរព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការប្រើប្រាស់សេវានិងផលិតផលហិរញ្ញវត្ថុ ព្រមទាំងធានាបាននូវកិច្ចការពារអតិថិជនប្រកបដោយប្រសិទ្ធភាព ទាន់ពេលវេលា និងមានសង្គតិភាព។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជា ក្រុមគ្រូបង្គោលថ្នាក់ឃុំ សមាជិក-សមាជិកនៃអង្គពិធីជាទីមេត្រី!**

គម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍" គិតមកដល់ពេលនេះ បានអនុវត្តសកម្មភាពជាបន្តបន្ទាប់ និងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ស្របតាមយុទ្ធសាស្ត្រជាតិ ស្ដីពី បរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ក្នុងការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅដល់សាធារណជននៅតាមមូលដ្ឋាន ក្នុងឃុំគោលដៅនានា។ ជាពិសេស គម្រោងនេះបានបណ្ដុះបណ្ដាលគ្រូបង្គោលតាមសហគមន៍ជាបន្តបន្ទាប់ ឱ្យក្លាយជាអ្នកផ្សព្វផ្សាយចំណេះដឹងនិងជាកម្លាំងដ៏សំខាន់ ក្នុងការចែករំលែកព័ត៌មានអំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុដោយយល់ដឹង ក៏ដូចជាការពារខ្លួនពីហានិភ័យផ្នែកហិរញ្ញវត្ថុ។ តាមរយៈសកម្មភាពទាំងនេះ គម្រោងបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ កាត់បន្ថយ

ហានិភ័យពីកម្ចីខុសច្បាប់ និងការបោកប្រាស់ផ្នែកហិរញ្ញវត្ថុ ព្រមទាំងចូលរួមពង្រឹងសុវត្ថិភាព និងសុខដុមរមនានៅក្នុងសហគមន៍។

វគ្គបណ្តុះបណ្តាលនេះ ពិតជាបានរៀបចំឡើងយ៉ាងល្អិតល្អន់ ដោយរួមបញ្ចូលទាំងមាតិកា ទ្រឹស្តី និងការអនុវត្តជាក់ស្តែង។ ក្នុងនោះ មានការផ្តល់នូវមូលដ្ឋានគ្រឹះនៃចំណេះដឹងផ្នែកហិរញ្ញវត្ថុ ព្រមទាំងការរៀបចំផែនការអនុវត្តការងារនៅតាមសហគមន៍ និងជំនាញក្នុងការកៀរគរនិងសម្របសម្រួលជាមួយប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព ដើម្បីជំរុញការចូលរួមរបស់សហគមន៍។ បន្ទាប់ពីការអនុវត្ត ក៏នឹងមានការរៀបចំរបាយការណ៍ជូនគណៈគ្រប់គ្រង ដើម្បីធ្វើការតាមដាន និងវាយតម្លៃលទ្ធផល។ ដំណើរការនេះ នឹងជួញឱ្យគម្រោងអាចបន្តកែលម្អជាបន្តបន្ទាប់ និងដាក់ចេញនូវយន្តការសមស្របនានា សំដៅលើកកម្ពស់ប្រសិទ្ធភាព និងនិរន្តរភាពនៃការអនុវត្តគម្រោង។

វត្តមានគ្រប់ភាគីពាក់ព័ន្ធក្នុងឱកាសនេះ បានបង្ហាញឱ្យឃើញពីស្មារតីនៃការខិតខំប្រឹងប្រែង និងការសហការជិតស្និទ្ធរវាងស្ថាប័នពាក់ព័ន្ធ និងគ្រូបង្គោលក្នុងការចូលរួមលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងពង្រឹងការការពារអតិថិជន ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន និងចីរភាពកម្ពុជា ដែលជាកិច្ចការមួយតម្រូវឱ្យមានការចូលរួម និងកិច្ចសហការរួមគ្នាពីគ្រប់ភាគីពាក់ព័ន្ធ ដូចដែលយើងកំពុងមានក្នុងថ្ងៃនេះ។

ហេតុដូចនេះ ខ្ញុំសង្ឃឹមថា គម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍" នេះ នឹងទទួលបានជោគជ័យជាងមុនទៀត ដើម្បីធានាថាចំណេះដឹងផ្នែកហិរញ្ញវត្ថុ សិទ្ធិ និងកិច្ចការពារអតិថិជន នឹងក្លាយជាកត្តាជំរុញកំណើនប្រកបដោយបរិយាបន្ន។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជា ក្រុមគ្រូបង្គោលថ្នាក់ឃុំ សមាជិក-សមាជិកនៃអង្គពិធីជាទីមេត្រី!**

ជាថ្មីម្តងទៀត ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការដឹកនាំថ្នាក់កណ្តាលនៃគម្រោង និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានយកចិត្តទុកដាក់ និងចូលរួមយ៉ាងសកម្មក្នុងការពង្រីកវិសាលភាពនៃគម្រោងនេះទៅកាន់ខេត្តនានា ដើម្បីបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងលើកកម្ពស់ការការពារអតិថិជននៅតាមមូលដ្ឋាន។

ដើម្បីបន្តសម្រេចបានជោគជ័យនៃគម្រោងបន្ថែមទៀត ខ្ញុំសូមលើកទឹកចិត្តដល់គ្រូបង្គោលទាំងអស់ឱ្យត្រងត្រាប់ស្តាប់នូវបទបង្ហាញរបស់វាគ្មិន ព្រមទាំងមេរៀននីមួយៗ ដោយយកចិត្តទុកដាក់និងលើកជាសំណួរឱ្យបានផុសផុល ដើម្បីទទួលបាននូវចំណេះដឹងពីភាគីពាក់ព័ន្ធបន្ថែមសម្រាប់ជាពុទ្ធិក្នុងការអនុវត្តការងារប្រចាំថ្ងៃប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនេះ គ្រូបង្គោលទាំងអស់ត្រូវបន្តដើរតួនាទីជាស្ពានភ្ជាប់សំខាន់



រវាងស្ថាប័នពាក់ព័ន្ធ និងសហគមន៍ ក្នុងការផ្សព្វផ្សាយ និងបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅដល់ប្រជាពលរដ្ឋ ឱ្យកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព។

ទន្ទឹមនេះ ដើម្បីជៀសវាងការរងគ្រោះពីករណីឆបោក និងការក្លែងបន្លំ (Scam និង Fraud) ខ្ញុំសូមអំពាវនាវដល់គ្រូបង្គោលទាំងអស់ ឱ្យមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការប្រើប្រាស់បណ្ដាញអ៊ីនធឺណិត និងមធ្យោបាយទំនាក់ទំនងផ្សេងៗ ដោយមិនគួរផ្ដល់ព័ត៌មាន ឬព័ត៌មានគណនីធនាគារទៅឱ្យប្រភពដែលមិនស្គាល់ ព្រមទាំងត្រូវផ្ទៀងផ្ទាត់ព័ត៌មានពីប្រភពផ្លូវការឱ្យបានច្បាស់លាស់ មុននឹងជឿ ឬអនុវត្តតាម ដើម្បីការពារខ្លួនឯង និងសហគមន៍ពីការរងគ្រោះដោយសារករណីឆបោក និងការក្លែងបន្លំ។

ខ្ញុំក៏សូមអំពាវនាវដល់គ្រូបង្គោលទាំងអស់ ឱ្យមានការប្រុងប្រយ័ត្នក្នុងការទទួល និងចែករំលែកព័ត៌មាន ព្រមទាំងត្រូវផ្ទៀងផ្ទាត់ព័ត៌មានពីប្រភពផ្លូវការ ដូចជា ធនាគារជាតិនៃកម្ពុជា និងសមាគមក្នុងវិស័យ មុននឹងជឿ ឬផ្សព្វផ្សាយបន្ត ដើម្បីជៀសវាងការភ័ន្តច្រឡំ និងរក្សាទំនុកចិត្តលើប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា។ បន្ថែមលើនេះ គ្រូបង្គោលទាំងអស់ គួរបន្តដើរតួនាទីជាអ្នកផ្សព្វផ្សាយព័ត៌មានត្រឹមត្រូវ និងចែករំលែកចំណេះដឹងដល់សហគមន៍ ដើម្បីបន្សាបព័ត៌មានមិនពិតដែលប៉ះពាល់សតិអារម្មណ៍ដល់ប្រជាពលរដ្ឋតាមមូលដ្ឋាន។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា សមាជិក-សមាជិកានៃអង្គពិធីទាំងអស់ សូមជួបនូវពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងសូមជូនពរដល់ក្រុមការងារពាក់ព័ន្ធទាំងអស់ទទួលបានជោគជ័យក្នុងដំណើរការវគ្គបណ្ដុះបណ្ដាលប្រកបដោយផ្លែផ្កា និងពិលាស។

ខ្ញុំសូមប្រកាសបើកកម្មវិធីវគ្គបណ្ដុះបណ្ដាលដល់គ្រូបង្គោលនៃគម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍" ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**

# សុន្ទរកថា
# ឯកឧត្តម យឹម លាត ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងទិវាប្រាក់រៀល ខួបលើកទី៤៦
# នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ

ថ្ងៃសុក្រ ២កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦

ឲឲឲ✵ៜៜៜ



**សូមគោរព**

- **ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីគោរពរាប់អាន!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយ និងកិត្តិយសយ៉ាងខ្លាំងចំពោះការអញ្ជើញចូលរួមរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ក្នុងកម្មវិធីដ៏មានអត្ថន័យនាថ្ងៃនេះ ដើម្បីអបអរសាទរខួបលើកទី៤៦ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ ព្រមទាំងសម្ពោធ និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវសំខាន់ៗចំនួនពីរ រវាងធនាគារជាតិនៃកម្ពុជា ជាមួយរដ្ឋសភាជាតិ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។

ថ្ងៃនេះ កាលពី ៤៦ឆ្នាំមុន គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់ ដែលប្រាក់រៀលត្រូវបានដាក់ឱ្យចរាចរឡើងវិញ បន្ទាប់ពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានបំបាត់រូបិយវត្ថុជាតិទាំងស្រុង។ ក្នុងដំណើរនៃការស្តារឡើងវិញនេះ ប្រាក់រៀលបានឆ្លងកាត់ឧបសគ្គជាច្រើន ជាពិសេសការបាត់បង់ទំនុកចិត្ត និងភាពទន់ខ្សោយនៃសេដ្ឋកិច្ច មុននឹងអាចបន្តពង្រឹងតួនាទីរបស់ខ្លួនឡើងវិញជាបន្តបន្ទាប់រហូតមានថ្ងៃនេះ។

ហេតុដូចនេះ ខ្ញុំសូមថ្លែងអំណរគុណ និងអបអរសាទរយ៉ាងជ្រាលជ្រៅចំពោះប្រជាជនកម្ពុជាទាំងមូល ដែលបានចូលរួមគាំទ្រ និងជឿជាក់លើប្រាក់រៀលជាបន្តបន្ទាប់។ ទំនុកចិត្តរបស់ប្រជាជន គឺជាមូលដ្ឋានដ៏រឹងមាំ ដែលបានគាំទ្រឱ្យប្រាក់រៀលអាចឈរជើងឡើងវិញ និងបន្តរីកចម្រើនយ៉ាងមាំមួនរហូតដល់សព្វថ្ងៃនេះ។

**អង្គពិធីជាទីមេត្រី!**

បើយើងក្រឡេកត្រឡប់ទៅកាន់ប្រវត្តិសាស្ត្រកម្ពុជា នឹងឃើញថា រូបិយវត្ថុតែងមានតួនាទីសំខាន់ក្នុងការពង្រឹងអធិបតេយ្យភាពជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ច។ ចាប់តាំងពីសម័យចេនឡា រហូតដល់សម័យអង្គរ សកម្មភាពសេដ្ឋកិច្ចភាគច្រើននៅតែពឹងផ្អែកលើការដោះដូរទំនិញ និងការប្រើប្រាស់រូបិយប័ណ្ណបរទេសមួយចំនួនតូច ដែលបង្ហាញថា នៅមិនទាន់មានរូបិយវត្ថុជាតិផ្លូវការនៅឡើយ។ ទោះជាយ៉ាងណា ព្រះមហាក្សត្រ

ខ្មែរ ទ្រង់បានខិតខំបង្កើតរូបិយវត្ថុជាតិជាបន្តបន្ទាប់ ប៉ុន្តែមិនអាចរក្សាបានយូរអង្វែង ដោយសារអស្ថិរភាពនយោបាយ និងសង្គ្រាម។ រហូតមកដល់សម័យអាណានិគមបារាំង កម្ពុជាបានចាប់ផ្តើមអភិវឌ្ឍប្រព័ន្ធរូបិយវត្ថុឡើងវិញឱ្យមានលក្ខណៈច្បាស់លាស់ជាងមុន ប៉ុន្តែដំណើរការនេះត្រូវបានរំខានដោយសង្គ្រាមជាបន្តបន្ទាប់ រហូតដល់ការលុបបំបាត់ប្រាក់រៀលទាំងស្រុងក្នុងរបប ប៉ុល ពត។ ដើម្បីយល់ឱ្យកាន់តែច្បាស់អំពីដំណើរវិវត្តន៍នេះ ខ្ញុំសូមលើកទឹកចិត្តឱ្យអង្គពិធីទាំងអស់ ទស្សនាសារមន្ទីរ ព្រះស្រីឧ្យសានវរ្ម័ន ដើម្បីស្វែងយល់បន្ថែមអំពីប្រវត្តិសាស្ត្រដ៏មានតម្លៃនេះ។

ប្រវត្តិសាស្ត្រកម្ពុជាបានបង្ហាញយ៉ាងច្បាស់ថា រូបិយវត្ថុជាតិគឺជាគ្រឹះសំខាន់មួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងភាពរឹងមាំរបស់ប្រទេស។ ក្នុងបរិបទនេះ គោលនយោបាយរូបិយវត្ថុមានតួនាទីជាស្នូលក្នុងការរក្សាស្ថិរភាពសេដ្ឋកិច្ច និងគាំទ្រកំណើន ខណៈដែលប្រាក់រៀល ជារូបិយវត្ថុជាតិ ដែលបំពេញមុខងារសំខាន់ក្នុងការទូទាត់ ការកំណត់តម្លៃ និងការសន្សំ។

ដូច្នេះ ដើម្បីពង្រឹង និងលើកកម្ពស់គោលនយោបាយរូបិយវត្ថុកម្ពុជាឱ្យកាន់តែរឹងមាំ និងអាចរីកចម្រើនប្រកបដោយចីរភាព ការសិក្សាស្រាវជ្រាវមានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រការរៀបចំគោលនយោបាយ និងជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែមានប្រសិទ្ធភាព។

ក្នុងន័យនេះ ខ្ញុំសូមចែករំលែកសង្ខេបអំពីលទ្ធផលស្រាវជ្រាវសំខាន់ៗចំនួនពីរ ដែលធនាគារជាតិនៃកម្ពុជា បានសហការ៖

ទី១ ស្តីពី "ដុល្លារូបនីយកម្ម និងផលប៉ះពាល់ក្នុងវិស័យកាត់ដេរ ផលិតស្បែកជើង ផលិតផលធ្វើដំណើរ និងកាបូបនៅកម្ពុជា" ជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។ ការសិក្សានេះត្រូវបានអនុវត្តឡើងក្នុងគោលបំណងស្វែងយល់ឱ្យបានច្បាស់ពីទំនាក់ទំនង រវាងលំហូរទុនវិនិយោគបរទេស និងការប្រើប្រាស់រូបិយវត្ថុក្នុងវិស័យនេះ ដែលមានការភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ ចាប់ពីការទទួលជាប្រាក់ដុល្លារអាមេរិក រហូតដល់ការបម្លែង និងការប្រើប្រាស់ប្រាក់រៀលក្នុងជីវភាពប្រចាំថ្ងៃ ដែលមានសារៈសំខាន់សម្រាប់ការរៀបចំគោលនយោបាយរូបិយវត្ថុ និងការលើកកម្ពស់តួនាទីរបស់ប្រាក់រៀល។ លទ្ធផលស្រាវជ្រាវបានបង្ហាញថា វិស័យនេះនៅតែពឹងផ្អែកខ្លាំងលើប្រាក់ដុល្លារអាមេរិក ជាពិសេសក្នុងការទទួលទុនវិនិយោគពីបរទេស និង





ការបើកប្រាក់ខែជាដុល្លារអាមេរិក ខណៈដែលកម្មករភាគច្រើនវិញចំណាយជាប្រាក់រៀលសម្រាប់ជីវភាពប្រចាំថ្ងៃ។ ភាពមិនត្រូវគ្នានៃរូបិយវត្ថុនេះ បានបង្កើតជាបន្ទុកបន្ថែមសម្រាប់កម្មករ ដោយពួកគេត្រូវបម្លែងប្រាក់ដោយខ្លួនឯង និងបាត់បង់ចំណូលប្រហែល ១,២% ជាពិសេសសម្រាប់អ្នកមានចំណូលទាប។ ទន្ទឹមនេះ ក៏មានសញ្ញាវិជ្ជមានថា កម្មករនិងសហគ្រាសមួយចំនួន កំពុងចាប់ផ្តើមប្តូរទិសដៅទៅរកការប្រើប្រាស់ប្រាក់រៀលកាន់តែច្រើន ប្រសិនបើមានស្ថិរភាពអត្រាប្តូរប្រាក់ និងប្រព័ន្ធទូទាត់មានភាពងាយស្រួល។ ដូច្នេះ ការសិក្សានេះមិនត្រឹមតែបង្ហាញពីបញ្ហាប្រឈមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ទិសដៅច្បាស់លាស់សម្រាប់ការកែលម្អ។ ក្នុងន័យនេះ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល មិនមែនជាជម្រើសទេ ប៉ុន្តែជាភាពចាំបាច់ដែលត្រូវអនុវត្តជាបន្តបន្ទាប់ ដើម្បីពង្រឹងប្រសិទ្ធភាពនៃគោលនយោបាយរូបិយវត្ថុ និងស្ថិរភាពសេដ្ឋកិច្ចជាតិ។

ទី២ ស្តីពី ការអង្កេតលើការប្រើប្រាស់រូបិយវត្ថុនៅក្នុងវិស័យសាធារណៈ ដែលជាគម្រោងសហការរវាងធនាគារជាតិនៃកម្ពុជា និងរដ្ឋសភាជាតិ។ ការសិក្សានេះមានគោលបំណងស្វែងយល់អំពីតួនាទី និងការចូលរួមរបស់វិស័យសាធារណៈក្នុងការគាំទ្រ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ជាពិសេសក្នុងប្រតិបត្តិការដែលទាក់ទងនឹងចំណូល-ចំណាយរដ្ឋ។ លទ្ធផលបានបង្ហាញថា ទោះបីកម្ពុជាមានកម្រិតដុល្លារូបនីយកម្មខ្ពស់ក៏ដោយ ក៏វិស័យសាធារណៈនៅតែប្រើប្រាស់ប្រាក់រៀលជាចម្បង។ ទោះយ៉ាងណា ក្នុងសកម្មភាពមួយចំនួនដែលពាក់ព័ន្ធនឹងបរទេស ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅតែមាន ហើយក៏បង្ហាញពីបញ្ហាប្រឈមមួយចំនួនដែលមានដូចជា ការសម្របសម្រួលមិនទាន់រឹងមាំ និងកង្វះទិន្នន័យ។ អ្វីដែលសំខាន់នោះ គឺលទ្ធផលនេះបានបញ្ជាក់ថា វិស័យសាធារណៈអាចក្លាយជាចំណុចចាប់ផ្តើមដ៏សំខាន់ ក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ។ ក្នុងន័យនេះ ការសិក្សាបានណែនាំឱ្យបន្តពង្រឹងការប្រើប្រាស់ប្រាក់រៀលក្នុងប្រតិបត្តិការរដ្ឋ តាមរយៈការអនុវត្តគម្រោងសាកល្បងក្នុងវិស័យសំខាន់ៗ ព្រមទាំងបង្កើតយន្តការសម្របសម្រួល និងប្រព័ន្ធចែករំលែកទិន្នន័យរវាងស្ថាប័នពាក់ព័ន្ធ ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព។

ក្នុងទិសដៅដែលបាននិងកំពុងបន្ត រាជរដ្ឋាភិបាលកម្ពុជា ដោយមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ជាស្ថាប័នដឹកនាំ កំពុងរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រថ្នាក់ជាតិ ស្តីពីការលើកកម្ពស់ប្រាក់រៀល។ យុទ្ធសាស្ត្រនេះនឹងកំណត់ទិសដៅ និងវិធានការជាក់លាក់ ដើម្បីធានាថា ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល អាចអនុវត្តបានយ៉ាងមានប្រសិទ្ធភាព និងសង្គតិភាព ព្រមទាំងធ្វើឱ្យការអនុវត្តគោលនយោបាយមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ។

ក្នុងន័យនេះ ខ្ញុំសូមអំពាវនាវដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញាទាំងអស់ចូលរួមគាំទ្រ និងប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ ព្រមទាំងជំរុញការប្រើប្រាស់ប្រាក់រៀលក្នុងវិស័យរបស់ខ្លួនឱ្យកាន់តែសកម្មថែមទៀត។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះភាគីពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមសហការនិងគាំទ្រយ៉ាងសកម្ម ក្នុងការស្រាវជ្រាវលើស្ថានភាពដុល្លាររូបនីយកម្ម និងការរៀបចំគោលនយោបាយលើកកម្ពស់ប្រាក់រៀល។ ជាពិសេស ខ្ញុំសូមថ្លែងអំណរគុណចំពោះរដ្ឋសភាជាតិ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនប្រចាំកម្ពុជា (JICA) មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារពិភពលោក (WB) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ដែលបានរួមចំណែកយ៉ាងសំខាន់ ក្នុងការគាំទ្រការស្រាវជ្រាវ និងការដាក់ចេញវិធានការគោលនយោបាយ សំដៅពង្រឹងតួនាទីប្រាក់រៀល ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា ទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងកម្មវិធីនាពេលនេះ និងសូមជូនពរឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើក ពិធីអបអរសាទរខួប ៤៦ឆ្នាំ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ ក្នុងពេលនេះ។

**សូមអរគុណ!**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៣៨.០២៦.០០២.សរ.ស.៣

## សេចក្តីជូនដំណឹង

បន្ទាប់ពីធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីណែនាំ លេខ ធ៣៧-០២៥-០២៧ សកណន ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ ស្តីពី វិធានការជួយសម្រាលបន្ទុកដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជម្លោះព្រំដែនកម្ពុជា-ថៃ ធនាគារជាតិនៃកម្ពុជាបានសង្កេតឃើញថា ការដាក់ពាក្យស្នើសុំការលើកលែងពាក់ព័ន្ធនឹងការទូទាត់សងឥណទានពីអតិថិជនដែលជាយោធិននិងជាជនភៀសសឹក មានការកើនឡើងកាន់តែច្រើន ដែលជាហេតុធ្វើឱ្យដំណើរការនៃការសម្របសម្រួលសំណើទាំងនោះមានការយឺតយ៉ាវពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

អាស្រ័យហេតុនេះ ដើម្បីលើកទឹកចិត្តដល់យោធិនជួរមុខ ដែលបំពេញបេសកកម្មការពារបូរណភាពទឹកដីក្នុងសមរភូមិប្រយុទ្ធ ធនាគារជាតិនៃកម្ពុជាស្នើសុំការអនុគ្រោះពីបងប្អូនជនភៀសសឹកទាំងអស់ ដោយផ្តល់អាទិភាពសម្របសម្រួលសំណើរបស់យោធិនជួរមុខ ជាមុនសិន។ ទន្ទឹមនេះ សម្រាប់យោធិនជួរមុខដែលបានដាក់ពាក្យស្នើសុំការលើកលែងរួចរាល់ ប៉ុន្តែមិនទាន់ទទួលបានការឆ្លើយតបពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សូមទាក់ទងមកលេខទូរសព្ទហាត់ឡាញរបស់ធនាគារជាតិនៃកម្ពុជាទីស្នាក់ការកណ្តាលដែលមានលេខ ០៨៥ ៦០០ ០០២/ ០៨៥ ៦០០ ០០៣/ ០៩៨ ២២០ ០០១/ ០៩៨ ២២០ ០០២ និង ០៩៧ ២៧៨ ៣០៣០។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគីពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

*ថ្ងៃព្រហស្បតិ៍ ១៣កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៦*

**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

(៨៥៥) ២៣ ៩៨០ ១៨៤
nbccommunications@nbc.gov.kh | www.nbc.gov.kh
ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia | National Bank of Cambodia
National Bank of Cambodia | nbccambodia
Natonal Bank of Cambodia | nationalbankofcambodia_

ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ០២៩...០២៦...០២៨...ធ.ជ.ណ.ស

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជម្រះបញ្ជីធនាគារព្រីនស៍ ម.ក

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា ធនាគារព្រីនស៍ ម.ក ត្រូវបានដាក់ឱ្យជម្រះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ធនាគារជាតិនៃកម្ពុជា បានតែងតាំងក្រុមហ៊ុនម៉ូរីសុនកាក់ អិមខេអេ អឌីត-អ៊ីខោនធីង ឯ.ក (Morisonkak MKA audit-accounting Co., Ltd)[១] ជាអ្នកជម្រះបញ្ជីធនាគារព្រីនស៍ ម.ក។ អាស្រ័យហេតុនេះ ធនាគារព្រីនស៍ ម.ក ត្រូវបានផ្អាកមិនឱ្យផ្តល់សេវាធនាគារថ្មីទៀតនោះទេ រួមទាំងការទទួលប្រាក់បញ្ញើ និងផ្តល់ឥណទាន។ ក្រុមហ៊ុនម៉ូរីសុនកាក់ អិមខេអេ អឌីត-អ៊ីខោនធីង ឯ.ក នឹងទទួលបានសិទ្ធិគ្រប់គ្រងនិងចាត់ចែងលើរាល់ប្រតិបត្តិការនិងទ្រព្យសម្បត្តិរបស់ធនាគារព្រីនស៍ ម.ក ចាប់ពីពេលជូនដំណឹងនេះតទៅ។

ចំពោះអតិថិជនដែលមានប្រាក់បញ្ញើនៅធនាគារព្រីនស៍ ម.ក គឺអាចទៅដកប្រាក់បានធម្មតា ដោយត្រូវរៀបចំឯកសារដើម្បីដកប្រាក់បញ្ញើ ដែលនឹងមានការចាត់ចែងជូនទៅតាមលំដាប់អាទិភាពស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ទន្ទឹមនេះ ចំពោះអ្នកខ្ចីប្រាក់ពីធនាគារព្រីនស៍ ម.ក គឺត្រូវបន្តបំពេញកាតព្វកិច្ចដែលមានជាប្រក្រតី។

ធនាគារជាតិនៃកម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងបន្តតាមដានយ៉ាងប្រុងប្រយ័ត្នខ្ពស់បំផុតលើការអនុវត្តរបស់អភិបាលកិច្ចបណ្តោះអាសន្ន ដើម្បីការពារផលប្រយោជន៍អ្នកដាក់ប្រាក់បញ្ញើក៏ដូចជាអតិថិជននានា។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦

**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
(៨៥៥) ២៣ ៩៩០ ១៨៤
nbccommunications@nbc.gov.kh | www.nbc.gov.kh
ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia | National Bank of Cambodia
National Bank of Cambodia | nbccambodia
Natonal Bank of Cambodia | nationalbankofcambodia_

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ [illegible]

ថ្ងៃ[illegible] ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៦

**ជម្រាបមក**

**លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា**

**គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**

**កម្មវត្ថុ** ៖ ការលើកលែងសោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំ ២០២៦ សម្រាប់សាខាស្រុករបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលមានទីតាំងក្នុង ១/-ខេត្តព្រះវិហារ ២/-ខេត្តបន្ទាយមានជ័យ ៣/-ខេត្តឧត្តរមានជ័យ ៤/-ខេត្តពោធិ៍សាត់ និង៥/-ខេត្តបាត់ដំបង។

**យោង** ៖ ប្រកាសលេខ ធ៧-០១៣-១២២ ប្រ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ មេត្តាជ្រាបថា ដើម្បីសម្រាលបន្ទុកដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលកំពុងរងផលប៉ះពាល់ខ្លាំងពីការវាយប្រហាររបស់យោធាថៃតាមព្រំដែន ធនាគារជាតិនៃកម្ពុជា សម្រេចលើកលែងសោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំ ២០២៦ សម្រាប់សាខាស្រុករបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលមានទីតាំងក្នុង ១/-ខេត្តព្រះវិហារ ២/-ខេត្តបន្ទាយមានជ័យ ៣/-ខេត្តឧត្តរមានជ័យ ៤/-ខេត្តពោធិ៍សាត់ និង៥/-ខេត្តបាត់ដំបង ដូចមាននៅក្នុងឧបសម្ព័ន្ធ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ជ្រាប និងចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាព។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ទទួលនូវការរាប់អានអំពីខ្ញុំ។

**ស.ម. ទេសាភិបាល**

**អគ្គនាយកត្រួតពិនិត្យ**

**គិត សុវណ្ណារិទ្ធ**

ប្រអប់សំបុត្រលេខ ២៥, អគារលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ ៖ (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ ៖ (៨៥៥-២៣) ៤២៦ ១១៧

**ឧបសម្ព័ន្ធ៖** លិខិតលេខ ធ១៧.០៦៦.០៤៨.អ.ភ.ណ ចុះថ្ងៃសុក្រ ១០រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៦

តារាងសាខាស្រុករបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលមានទីតាំងក្នុង ១/-ខេត្តព្រះវិហារ ២/-ខេត្តបន្ទាយមានជ័យ ៣/-ខេត្តឧត្តរមានជ័យ ៤/-ខេត្តពោធិ៍សាត់ និង ៥/-ខេត្តបាត់ដំបង។

| | |
|---|---|
| **១- ខេត្តព្រះវិហារ** | |
| ១ | ស្រុកជ័យសែន |
| ២ | ស្រុកឆែប |
| ៣ | ស្រុកជាំក្សាន្ត |
| ៤ | ស្រុកគូលែន |
| ៥ | ស្រុករវៀង |
| ៦ | ស្រុកសង្គមថ្មី |
| **២- ខេត្តបន្ទាយមានជ័យ** | |
| ១ | ស្រុកមង្គលបុរី |
| ២ | ស្រុកភ្នំស្រុក |
| ៣ | ស្រុកព្រះនេត្រព្រះ |
| ៤ | ស្រុកអូរជ្រៅ |
| ៥ | ស្រុកថ្មពួក |
| ៦ | ស្រុកស្វាយចេក |
| ៧ | ស្រុកម៉ាឡៃ |
| **៣- ខេត្តឧត្តរមានជ័យ** | |
| ១ | ស្រុកអន្លង់វែង |
| ២ | ស្រុកបន្ទាយអំពិល |
| ៣ | ស្រុកចុងកាល់ |
| ៤ | ស្រុកត្រពាំងប្រាសាទ |
| **៤- ខេត្តពោធិ៍សាត់** | |
| ១ | ស្រុកវាលវែង |
| **៥- ខេត្តបាត់ដំបង** | |
| ១ | ស្រុកសំពៅលូន |
| ២ | ស្រុកកំរៀង |
| ៣ | ស្រុកភ្នំព្រឹក |
| ៤ | ស្រុកសំឡូត |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ០៣៣..០៤.៦..១០៦..នន.ជ.ណ

## សេចក្តីជូនដំណឹង

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា តម្លៃកាសប្រាក់សុទ្ធត្រូវបានកែសម្រួលឱ្យសមស្របតាមការកើនឡើងថ្លៃប្រាក់សុទ្ធលើទីផ្សារ ដោយបានកំណត់ថ្លៃលក់កាសប្រាក់សុទ្ធចំនួន៦ប្រភេទ ដូចខាងក្រោម៖

| ល.រ | រូបកាស | ឈ្មោះកាសអនុស្សាវរីយ៍ | តម្លៃចាស់ | តម្លៃថ្មី |
|---|---|---|---|---|
| ១ |  | កាស អាស៊ាន<br>ASEAN Community 2015 | ២២៣.០០០៛<br>(ពីររយម្ភៃបីពាន់រៀល) | ៥៥០.០០០៛<br>(ប្រាំរយហាសិបពាន់រៀល) |
| ២ |  | កាសខួបទី៦០ឆ្នាំ មិត្តភាពកម្ពុជា-ជប៉ុន<br>60th Anniversary of Friendship between Japan and Cambodia | ២២៣.០០០៛<br>(ពីររយម្ភៃបីពាន់រៀល) | ៥៥០.០០០៛<br>(ប្រាំរយហាសិបពាន់រៀល) |
| ៣ |  | កាសរូបព្រះអាទិត្យរះ<br>Cambodia Sunrise Silver Coin | ១៨០.០០០៛<br>(មួយរយប៉ែតសិបពាន់រៀល) | ៣៥០.០០០៛<br>(បីរយហាសិបពាន់រៀល) |
| ៤ |  | កាសប្រាក់ប្រាសាទ<br>Ancient Cambodian Silver Proof Coin | ១៨០.០០០៛<br>(មួយរយប៉ែតសិបពាន់រៀល) | ៣៥០.០០០៛<br>(បីរយហាសិបពាន់រៀល) |
| ៥ |  | កាសប្រាក់ស្លឹងប្រាក់<br>Cambodia Ancient Naga Coin | ១៨០.០០០៛<br>(មួយរយប៉ែតសិបពាន់រៀល) | ៣៥០.០០០៛<br>(បីរយហាសិបពាន់រៀល) |
| ៦ |  | កាសរូបព្រះបាទនរោត្តម<br>Cambodian Silver Proof Coin | ១៨០.០០០៛<br>(មួយរយប៉ែតសិបពាន់រៀល) | ៣៥០.០០០៛<br>(បីរយហាសិបពាន់រៀល) |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

*ថ្ងៃអង្គារ ៩កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦*

**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
(៨៥៥) ១១ ៧០៥ ៩៥៩ (លោក ឆាង ពៅ)
nbccommunications@nbc.gov.kh | www.nbc.gov.kh
ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia | National Bank of Cambodia
National Bank of Cambodia | nbccambodia
Natonal Bank of Cambodia | nationalbankofcambodia_

ប្រអប់សំបុត្រលេខ ២៥, ផ្ទះលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៥២៦ ១១៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ២៨...០៤៦...០០៥...ប្រកាសព័ត៌មាន

ថ្ងៃអង្គារ ៦កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ស្ថានភាពមិនស្របច្បាប់របស់កម្មវិធី PAI ឬ PaiPay**

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន មេត្តាជ្រាបថា នាពេលថ្មីៗនេះ ធនាគារជាតិនៃកម្ពុជា បានសង្កេតឃើញមានកម្មវិធី PAI ឬ PaiPay កំពុងដាក់ឱ្យដំណើរការលើផ្លែតហ្វមតេឡេក្រាម (Telegram) ដែលមានលក្ខណៈជា Chat Bot និងអាចទាញយកពី App Store និង Google Play Store ហើយកម្មវិធីនេះមានមុខងារបង្កើតគណនី (Wallet) ដាក់ប្រាក់ចូលគណនី ផ្ទេរប្រាក់ និងទូទាត់សងប្រាក់ ដោយមិនមានការគ្រប់គ្រងត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា ក៏បានសង្កេតឃើញអំពី ការផ្សព្វផ្សាយពាណិជ្ជកម្មកម្មវិធី PAI ឬ PaiPay តាមរយៈបណ្តាញសង្គមតេឡេក្រាម និងនៅតាមទីតាំងមួយចំនួននៅក្នុងរាជធានីភ្នំពេញ និងខេត្តព្រះសីហនុផងដែរ។

ធនាគារជាតិនៃកម្ពុជា សូមបញ្ជាក់ថា កម្មវិធី PAI ឬ PaiPay ខាងលើនេះ ពុំមែនជាកម្មវិធីទូទាត់ចល័តរបស់គ្រឹះស្ថានដែលមានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជានោះទេ។ អាស្រ័យហេតុនេះ សូម សាធារណជន មេត្តាជ្រាបជាព័ត៌មាន និងមានការប្រុងប្រយ័ត្នខ្ពស់អំពីការឆបោកតាមប្រព័ន្ធអនឡាញ ដែលអាចបណ្តាលឱ្យប្រឈមនឹងហានិភ័យដោយប្រការណាមួយ។ សម្រាប់ករណីនេះ ធនាគារជាតិនៃកម្ពុជា ក៏បាននិងកំពុងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់វិធានការស្រាវជ្រាវ និងបង្ក្រាបការផ្សព្វផ្សាយមិនស្របច្បាប់របស់កម្មវិធីមួយនេះផងដែរ។

**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

(៨៥៥) ២៣ ៩៩០ ១៨៤
nbccommunications@nbc.gov.kh | www.nbc.gov.kh
ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia | National Bank of Cambodia
National Bank of Cambodia | nbccambodia
Natonal Bank of Cambodia | nationalbankofcambodia_

ប្រអប់សំបុត្រលេខ ២៥, អគារលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ ៖ (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ ៖ (៨៥៥-២៣) ៤២៦ ១១៧

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា និង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហប្រធាននៃអនុគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា (អ.គ.ជ.ស.) ដឹកនាំកិច្ចប្រជុំអនុគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុ



នាថ្ងៃពុធ ៧កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និង **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហប្រធាននៃអនុគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា (អ.គ.ជ.ស.) ដឹកនាំកិច្ចប្រជុំអនុគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កិច្ចប្រជុំនេះមានការចូលរួមពីសមាជិក និងសមាជិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីពិនិត្យ និងពិភាក្សាពីវឌ្ឍនភាព បញ្ហាប្រឈម និងកាលនុវត្តភាពនៃវិស័យហិរញ្ញវត្ថុកម្ពុជា ឆ្នាំ២០២៥ និងទស្សនវិស័យសម្រាប់ឆ្នាំ២០២៦ សំដៅបន្តរក្សាស្ថិរភាពហិរញ្ញវត្ថុកម្ពុជាប្រកបដោយប្រសិទ្ធភាព។





# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូជាន់ខ្ពស់នៃធនាគារកណ្តាលប៉ាពួញូហ្គីណេ ដែលមកបំពេញទស្សនកិច្ចនៅកម្ពុជា



*លោកជំទាវបណ្ឌិត ជា សិរី*
*ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*លោកជំទាវ Elizabeth Genia*
*ទេសាភិបាល ធនាគារកណ្តាលប៉ាពួញូហ្គីណេ*

នាថ្ងៃពុធ ១១រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូជាន់ខ្ពស់នៃធនាគារកណ្តាលប៉ាពួញូហ្គីណេ ដែលកំពុងបំពេញទស្សនកិច្ចនៅកម្ពុជា ដឹកនាំដោយ**លោកជំទាវទេសាភិបាល** Elizabeth Genia នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ គោលបំណងនៃដំណើរទស្សនកិច្ចនេះគឺដើម្បីសិក្សាស្វែងយល់ពីបទពិសោធនៃការគ្រប់គ្រងប្រព័ន្ធធនាគារកម្ពុជា ការអភិវឌ្ឍប្រព័ន្ធទូទាត់ និងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ក្នុងជំនួបនេះ លោកជំទាវទេសាភិបាល Elizabeth Genia បានថ្លែងអំណរគុណចំពោះការទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅនៅកម្ពុជា និងបានលើកសរសើរពីការអភិវឌ្ឍប្រព័ន្ធទូទាត់ឌីជីថលនៅកម្ពុជា ដែលជាប្រទេសឈានមុខគេមួយនៅក្នុងតំបន់។ លោកជំទាវបានសង្កត់ធ្ងន់ពីភាពចាំបាច់នៃការលើកកម្ពស់ប្រព័ន្ធទូទាត់អន្តរធនាគារ ដូចដែលកម្ពុជាសម្រេចបានយ៉ាងជោគជ័យ និងសារៈសំខាន់នៃការទទួលបានកិច្ចសហការចែករំលែក





បទពិសោធគន្លឹះល្អៗពីធនាគារជាតិនៃកម្ពុជា។ នាឱកាសនេះ លោកជំទាវបណ្ឌិត ជា សិរី បានបង្ហាញការស្វាគមន៍ និងជម្រាបជូនពីការទទួលបានដំណើរទស្សនកិច្ចរបស់គណៈប្រតិភូបណ្ដាធនាគារកណ្ដាលជាច្រើននាពេលកន្លងមក។ លោកជំទាវបានមានប្រសាសន៍ពីវឌ្ឍនភាពល្អប្រសើរពាក់ព័ន្ធនឹងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ បន្ទាប់ពីការដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់អន្តរធនាគារ ដែលបានធ្វើឱ្យស្ថាប័នអន្តរជាតិនានាផ្ដល់ការវាយតម្លៃខ្ពស់អំពីវឌ្ឍនភាពនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុក្នុងការសម្រួលដល់ការរស់នៅប្រចាំថ្ងៃនិងការធ្វើអាជីវកម្ម។ ជារួម ភាគីទាំងពីរបានឯកភាពលើការបន្តលើកកម្ពស់កិច្ចសហការឱ្យបានកាន់តែប្រសើរថែមទៀត។ បន្ទាប់ពីជំនួបនេះ គណៈប្រតិភូធនាគារកណ្ដាលប៉ាពូញូហ្គីណេ ក៏បានទៅទស្សនាសារមន្ទីរព្រះស្រីឰសានវរ្ម័ន ដែលបង្ហាញពីប្រវត្តិសេដ្ឋកិច្ច និងរូបិយវត្ថុកម្ពុជាតាំងពីសតវត្សរ៍ទី១ រហូតមកទល់បច្ចុប្បន្ន ផងដែរ។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបពិភាក្សាការងារ ជាមួយគណៈប្រតិភូនៃអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO)



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*លោក Yasuto Watanabe ប្រធាន អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO)*

នាថ្ងៃព្រហស្បតិ៍ ៤កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែមករា ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបពិភាក្សាការងារ ជាមួយគណៈប្រតិភូនៃ អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ដឹកនាំដោយ **លោកប្រធាន** Yasuto Watanabe នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ ក្នុងជំនួបនេះ លោកជំទាវទេសាភិបាល និងលោកប្រធានបានផ្លាស់ប្តូរទស្សនាទានអំពីស្ថានភាពសេដ្ឋកិច្ចកម្ពុជាព្រមទាំងកត្តាប្រឈមការអភិវឌ្ឍប្រព័ន្ធទូទាត់កម្ពុជា និងការប្រើប្រាស់បញ្ញាសិប្បនិម្មិតជាដើម។ លោកប្រធាន Yasuto បានលើកសរសើរពីវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធទូទាត់ឌីជីថលនៅកម្ពុជា ដោយបញ្ជាក់ថាមានប្រទេសជាច្រើន



បានយកជាគំរូសម្រាប់ធ្វើការអភិវឌ្ឍប្រព័ន្ធទូទាត់ និងបានបញ្ជាក់ពីឆន្ទៈក្នុងការបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយធនាគារជាតិនៃកម្ពុជាឱ្យបានកាន់តែប្រសើរថែមទៀត។ ជាការឆ្លើយតប លោកជំទាវបានមានប្រសាសន៍ពីកិច្ចសហការល្អរវាងភាគីទាំងពីរនាពេលកន្លងមក និងបានថ្លែងអំណរគុណ AMRO ដែលបានគាំទ្រដល់ការលើកកម្ពស់សមត្ថភាពមន្ត្រីបុគ្គលិក ធនាគារជាតិនៃកម្ពុជា។ លោកជំទាវក៏បានលើកឡើងពីការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ និងការអភិវឌ្ឍមុខងារប្រកបដោយនវានុវត្តន៍ ដែលផ្តល់ភាពអំណោយផលដល់ការលើកកម្ពស់ប្រាក់រៀលនិងបរិយាបន្នហិរញ្ញវត្ថុ។ ពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ច ភាគីទាំងពីរបានកត់សម្គាល់ពីនិន្នាការវិជ្ជមាននៃកំណើនការនាំចេញរបស់កម្ពុជា ដោយមានផលិតផលកាន់តែសម្បូរបែប និងទីផ្សារកាន់តែច្រើនឡើង បើទោះបីជាវិស័យសំណង់និងអចលនទ្រព្យនៅមិនទាន់រឹងមាំក្តី។





# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារប្រធានការិយាល័យតំបន់អាស៊ីនិរតី និងប្រជុំកោះប៉ាស៊ីហ្វិក និងសហការី នៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*លោកស្រី Keiko Miwa ប្រធានការិយាល័យតំបន់អាស៊ីនិរតីនិង ប្រជុំកោះប៉ាស៊ីហ្វិក នៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)*

នាថ្ងៃព្រហស្បតិ៍ ៣រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយ**លោកស្រី Keiko Miwa** ប្រធានការិយាល័យតំបន់អាស៊ីនិរតី និងប្រជុំកោះប៉ាស៊ីហ្វិក និងសហការី នៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ លោកស្រី Keiko Miwa បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរវាង IFC និង ធនាគារជាតិនៃកម្ពុជា នាពេលកន្លងមក ព្រមទាំងការស្វែងយល់បន្ថែមពីវឌ្ឍនភាពនៃប្រព័ន្ធធនាគារនៅកម្ពុជា។ លោកស្រីក៏បានបន្ថែមថា IFC ត្រៀមខ្លួនក្នុងការសហការនានា ដើម្បីលើកកម្ពស់ដល់ការកសាងប្រព័ន្ធធនាគារនៅកម្ពុជាប្រកបដោយស្ថិរភាព និងសុវត្ថិភាព ស្របតាមស្តង់ដារអន្តរជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។ ជាការឆ្លើយតប លោកជំទាវទេសាភិបាលបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហការល្អរវាងភាគីទាំងពីរនាពេលកន្លងមក និងបានថ្លែងអំណរគុណ IFC ដែលបានគាំទ្រដល់ធនាគារជាតិនៃកម្ពុជា តាមរយៈការពង្រឹងសមត្ថភាព និងជំនួយបច្ចេកទេស ព្រមទាំងបានស្នើសុំការគាំទ្របន្ថែមទៀតដល់ការរៀបចំយន្តការគ្រប់គ្រងគុណភាពឥណទាន ក៏ដូចផ្នែកទំនាក់ទំនងគោលនយោបាយផងដែរ។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយលោកស្រី Vladanka Andreeva អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដែលទើបត្រូវបានតែងតាំង និងសហការី



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*លោកស្រី Vladanka Andreeva អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា*

នាថ្ងៃព្រហស្បតិ៍ ៣រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយ **លោកស្រី** Vladanka Andreeva អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដែលទើបត្រូវបានតែងតាំង និងសហការី នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ លោកស្រី Vladanka Andreeva បានបង្ហាញពីចំណាប់អារម្មណ៍លើការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា និងបានស្វែងយល់ពីបញ្ហាប្រឈម ព្រមទាំងបានសម្តែងការប្តេជ្ញាចិត្តបន្តពង្រឹងកិច្ចសហការក្នុងការគាំទ្រសេដ្ឋកិច្ចកម្ពុជា ដើម្បីរួមចំណែកលើកកម្ពស់កម្រិតជីវភាពប្រជាជន និងកាត់បន្ថយភាពក្រីក្រ។ បន្ថែមលើនេះ លោកស្រីនឹងបន្តគាំទ្រធនាគារជាតិនៃកម្ពុជាតាមរយៈការចូលរួមជាមួយពហុភាគីពាក់ព័ន្ធ ដើម្បីរួមគ្នាពង្រឹងបន្ថែមនូវកិច្ចការពារអតិថិជនក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ជាការឆ្លើយតបលោកជំទាវទេសាភិបាលបានថ្លែងអំណរគុណដល់អង្គការសហប្រជាជាតិដែលបានគាំទ្រធនាគារជាតិនៃកម្ពុជានាពេលកន្លងមកព្រមទាំងបានស្នើសុំការគាំទ្របន្ថែមទៀត ដើម្បីលើកកម្ពស់សុខមាលភាពប្រជាជន និងប្រព័ន្ធធនាគារប្រកបដោយចីរភាព។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយលោកស្រី Yasmin Siddiqi នាយិកាធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំប្រទេសកម្ពុជា និងសហការី



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*លោកស្រី Yasmin Siddiqi នាយិកា ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំប្រទេសកម្ពុជា*

នាថ្ងៃព្រហស្បតិ៍ ៣រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយ **លោកស្រី** Yasmin Siddiqi និងសហការី ក្នុងឱកាសលោកស្រីត្រូវបានតែងតាំងជានាយិកា ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំប្រទេសកម្ពុជា នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ ក្នុងជំនួបនេះ លោកជំទាវទេសាភិបាល និងលោកស្រីនាយិកាបានផ្លាស់ប្តូរទស្សនាទានអំពីស្ថានភាពសេដ្ឋកិច្ចកម្ពុជានិងកត្តាប្រឈម ការអភិវឌ្ឍប្រព័ន្ធទូទាត់កម្ពុជា និងការប្រើប្រាស់បញ្ញាសិប្បនិម្មិតជាដើម។ លោកស្រី Yasmin Siddiqi បានលើកឡើងពីភាពធន់នៃសេដ្ឋកិច្ចកម្ពុជា ព្រមទាំងវឌ្ឍនភាពដ៏ល្អប្រសើរលើការលើកកម្ពស់បរិយាបន្ន និងចំណេះដឹងហិរញ្ញវត្ថុ តាមរយៈការបញ្ចូលក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ និងបានបញ្ជាក់ពីឆន្ទៈក្នុងការបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយធនាគារជាតិនៃកម្ពុជាឱ្យបានកាន់តែរឹងមាំថែមទៀត។ ជាការឆ្លើយតប លោកជំទាវទេសាភិបាលបានមានប្រសាសន៍ពីកិច្ចសហការល្អរវាងភាគីទាំងពីរនាពេលកន្លងមក និងបានថ្លែងអំណរគុណធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានគាំទ្រដល់ដំណើការរៀបចំប្រតិបត្តិការមជ្ឈមណ្ឌលការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ដំណើការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ២០២៦-២០៣០ និងសកម្មភាពពាក់ព័ន្ធនឹងចិរភាពហិរញ្ញវត្ថុ។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់ធនាគារហត្ថា ដឹកនាំដោយលោក Kenichi Yamato តំណាងភាគទុនិក ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*លោក Kenichi Yamato តំណាងភាគទុនិក ធនាគារហត្ថា*

នាថ្ងៃចន្ទ ១៤កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២ ខែមីនា ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់ធនាគារហត្ថា ដឹកនាំដោយ**លោក** Kenichi Yamato តំណាងភាគទុនិក ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ គោលបំណងនៃជំនួបនេះគឺដើម្បីឱ្យគណៈប្រតិភូធនាគារ ហត្ថា បានជម្រាបជូនអំពីវឌ្ឍនភាពនៃប្រតិបត្តិការរបស់ធនាគារ ក៏ដូចជាផែនការអាជីវកម្មរបស់ធនាគារ ព្រមទាំងការធ្វើបច្ចុប្បន្នភាពប្រតិបត្តិការសាខា។ ក្នុងជំនួបនេះ លោក Kenichi បានជម្រាបជូនពីស្ថានភាពប្រតិបត្តិការរបស់ធនាគារ កត្តាប្រឈមមួយចំនួន និងផែនការប្រតិបត្តិការរយៈពេលវែង។ លោកក៏បានបង្ហាញពីការយកចិត្តទុកដាក់ក្នុងការប្រកាន់ខ្ជាប់នូវអនុលោមភាពស្របតាមបទប្បញ្ញត្តិនានា និងអាទិភាពនៃការគ្រប់គ្រងប្រតិបត្តិការប្រកបដោយចីរភាព។ ជាការឆ្លើយតប លោកជំទាវទេសាភិបាលបានផ្តល់អនុសាសន៍មួយចំនួនទៅលើផែនការដែលបានលើកឡើង និងបានលើកទឹកចិត្តបន្តរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារផងដែរ។ លោកជំទាវក៏បានបញ្ជាក់អំពីសារៈសំខាន់នៃការរក្សាបានបណ្តាញសាខា និងធនធានមនុស្សគ្រប់គ្រាន់ដើម្បីគាំទ្រដល់ផែនការនៃការធ្វើប្រតិបត្តិការរបស់ធនាគារ ស្របពេលដែលគ្រឹះស្ថានកំពុងធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យា។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូក្រុមប្រឹក្សាធុរកិច្ចសហភាពអឺរ៉ុប-អាស៊ាន (EU-ABC)



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*លោកស្រី Sharon Toh អនុប្រធានក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាធុរកិច្ចសហភាព អឺរ៉ុប-អាស៊ាន*

នាថ្ងៃពុធ ១រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូក្រុមប្រឹក្សាធុរកិច្ចសហភាពអឺរ៉ុប-អាស៊ាន (EU-ABC) ដឹកនាំដោយ**លោកស្រី Sharon Toh** អនុប្រធានក្រុមប្រឹក្សាភិបាល អមដោយថ្នាក់ដឹកនាំជាន់ខ្ពស់សភាពាណិជ្ជកម្មអឺរ៉ុបប្រចាំកម្ពុជា និងតំណាងក្រុមហ៊ុនអឺរ៉ុបធំៗ នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ កិច្ចពិភាក្សានេះមានគោលបំណងស្វែងរកកិច្ចសហការថ្មីៗថែមទៀត ដើម្បីលើកកម្ពស់ទំនាក់ទំនងផ្នែកធុរកិច្ចនិងវិនិយោគរវាងសហភាពអឺរ៉ុបនិងប្រទេសកម្ពុជា ជាពិសេសក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ ក្នុងជំនួបនេះ លោកជំទាវទេសាភិបាលបានមានប្រសាសន៍អំពីវឌ្ឍនភាពប្រព័ន្ធធនាគារកម្ពុជា ការរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងគាំទ្រដល់ការធ្វើពាណិជ្ជកម្ម និងការវិនិយោគ។ បន្ថែមលើនេះ លោកជំទាវក៏បានគូសបញ្ជាក់ពីការអភិវឌ្ឍប្រព័ន្ធទូទាត់ឌីជីថលនិងការសម្រេចការតភ្ជាប់ជាមួយប្រទេសសក្តានុពលនានា ដែលផ្តល់ភាពអំណោយផលដល់ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងបរិយាបន្នហិរញ្ញវត្ថុ។ លោកជំទាវក៏បានថ្លែងអំណរគុណដល់





បណ្ដាក្រុមហ៊ុនអឺរ៉ុបដែលបានវិនិយោគ និងពង្រីកផលិតកម្មនៅកម្ពុជា និងស្នើឱ្យបង្កើនការវិនិយោគឱ្យបានកាន់តែច្រើនថែមទៀត។ ក្នុងឱកាសនេះ លោកស្រី Sharon Toh បានលើកឡើងពីសុទិដ្ឋិនិយមរបស់គណៈប្រតិភូ EU-ABC ចំពោះសក្ដានុពលសេដ្ឋកិច្ចកម្ពុជា និងបានលើកសរសើរពីការបំពេញតួនាទីបានយ៉ាងល្អរបស់ ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពប្រព័ន្ធធនាគារ ជាពិសេសការអភិវឌ្ឍប្រព័ន្ធទូទាត់ឌីជីថល។ ទន្ទឹមនឹងការលើកឡើងពីកត្តាប្រឈមមួយចំនួន គណៈប្រតិភូ EU-ABC ក៏បានគូសបញ្ជាក់ពីការតាំងចិត្តបន្តពង្រឹងកិច្ចសហប្រតិបត្តិការថែមទៀត ជាពិសេសលើការវិនិយោគដើម្បីពង្រឹងភាពប្រកួតប្រជែងផ្នែកពាណិជ្ជកម្ម ការអភិវឌ្ឍហិរញ្ញវត្ថុប្រកបដោយចីរភាព និងផ្សារមូលបត្រជាដើម។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យក្រុមបេសកកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដឹកនាំដោយលោក Kenichiro Kashiwase ប្រធានក្រុមបេសកកម្មសម្រាប់កម្ពុជា ចូលជួបសម្តែងការគួរសម



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*លោក Kenichiro Kashiwase ប្រធានក្រុមបេសកកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិសម្រាប់កម្ពុជា*

នាថ្ងៃព្រហស្បតិ៍ ២រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យក្រុមបេសកកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដឹកនាំដោយ **លោក** Kenichiro Kashiwase ប្រធានក្រុមបេសកកម្មសម្រាប់កម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបជូនអំពីគោលបំណងនៃបេសកកម្ម (Staff Visit) ប្រចាំឆ្នាំ២០២៦ នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ បេសកកម្មនេះ ធ្វើឡើងក្នុងគោលបំណងពិភាក្សាជាមួយអាជ្ញាធរ និងវិស័យឯកជន ដើម្បីស្វែងយល់ពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ស្ថានភាពហិរញ្ញវត្ថុ ទស្សនវិស័យនាពេលអនាគត និងគោលនយោបាយនានា។ ក្នុងជំនួបនេះ លោកជំទាវទេសាភិបាលបានជម្រាបជូនពីស្ថានភាពសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២៥ ដោយបានគូសបញ្ជាក់ពីការរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់ល្អប្រសើរ និងកម្រិតទាបនៃអត្រាអតិផរណា។ លើសពីនេះ លោកជំទាវក៏បានលើកឡើងពីការដាក់ចេញវិធានការនានាជាបន្តបន្ទាប់ សំដៅផ្តល់ជាដំណោះស្រាយលើបញ្ហាប្រឈមចម្រុងៗ ដូចជាបញ្ហាកើតចេញពីជម្លោះព្រំដែន ការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងការដាក់ឱ្យ





ជម្រះបញ្ជីសម្រាប់គ្រឹះស្ថានធនាគារស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ជាដើម។ ក្នុងឱកាសនេះដែរ លោក Kenichiro បានជម្រាបជូនលោកជំទាវទេសាភិបាល ពីគោលបំណងរបស់ក្រុមការងារដែលមកបំពេញបេសកកម្មនាពេលនេះ ជាពិសេសការគាំទ្ររបស់ IMF ក្នុងការចូលរួមអភិវឌ្ឍវិស័យធនាគារ ក៏ដូចជាការផ្តល់ជំនួយបច្ចេកទេស អាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលនានាសម្រាប់អភិវឌ្ឍសមត្ថភាពមន្ត្រី-បុគ្គលិកឱ្យបានកាន់តែប្រសើរថែមទៀត។

គួររំលេចថា បន្ទាប់ពីបានជួបសម្តែងការគួរសមជាមួយលោកជំទាវទេសាភិបាលរួចមក ក្រុមបេសកកម្មក៏បានជួបពិភាក្សាថ្នាក់បច្ចេកទេសជាមួយថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ទៅលើស្ថានភាពនិងទស្សន-វិស័យសេដ្ឋកិច្ចកម្ពុជា វឌ្ឍនភាពប្រព័ន្ធធនាគារ និងបញ្ហាប្រឈមនានាផងដែរ។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូ ធនាគារពិភពលោក ដឹកនាំដោយលោក Carlos Felipe Jaramillo អនុប្រធាន ធនាគារពិភពលោកទទួលបន្ទុកតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*លោក Carlos Felipe Jaramillo អនុប្រធាន ធនាគារពិភពលោក ទទួលបន្ទុកតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក*

នាថ្ងៃអង្គារ ១៤រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូ ធនាគារពិភពលោក ដឹកនាំដោយ**លោក** Carlos Felipe Jaramillo អនុប្រធាន ធនាគារពិភពលោកទទួលបន្ទុកតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក នៅធនាគារជាតិនៃកម្ពុជា អាគារវត្តភ្នំ។ ក្នុងជំនួបនេះ លោក Jaramillo បានបញ្ជាក់ពីការកត់សម្គាល់លើសក្តានុពលសេដ្ឋកិច្ចកម្ពុជាក្នុងវិស័យសំខាន់ៗមួយចំនួន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ បន្ថែមលើនេះ លោកក៏បានបញ្ជាក់ពីក្តីសោមនស្សចំពោះកិច្ចសហការល្អរវាងស្ថាប័នទាំងពីរនាពេលកន្លងមកផងដែរ។ ជាការឆ្លើយតប លោកជំទាវទេសាភិបាល បានមានប្រសាសន៍ពីតួនាទីរបស់វិស័យធនាគារក្នុងការចូលរួមជំរុញការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈការលើកកម្ពស់លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ និងស្ថិរភាពប្រព័ន្ធធនាគារ។ ទន្ទឹមនេះ លោកជំទាវក៏បានលើកឡើងពីកត្តាប្រឈមមួយចំនួន និងបានផ្លាស់ប្តូរទស្សនាទានពីការវិវត្តនៃស្ថានភាពភូមិសាស្ត្រនយោបាយសកល រួមទាំងការប្រែប្រួលតម្លៃប្រេងលើទីផ្សារអន្តរជាតិផងដែរ។ បន្ថែមលើនេះ លោកជំទាវក៏បានជម្រាបពីការទទួលបានកិច្ចសហការល្អពីខាងធនាគារពិភពលោកលើកិច្ចការរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិ និងយុទ្ធសាស្ត្រជាតិនានាពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ។ ជារួម ភាគីទាំងពីរបានបញ្ជាក់ពីការប្តេជ្ញាក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរឱ្យបានកាន់តែរឹងមាំថែមទៀត សំដៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។ គួររំលេចថា បន្ទាប់ពីកិច្ចពិភាក្សានេះ គណៈប្រតិភូធនាគារពិភពលោក ក៏បានទៅទស្សនាសារមន្ទីសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីល្បសាន្តវរ្ម័នផងដែរ។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់ធនាគារចិន ដឹកនាំដោយលោក Sun Yu នាយកប្រតិបត្តិ ធនាគារចិន ប្រចាំទីក្រុងហុងកុង ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*លោក Sun Yu នាយកប្រតិបត្តិ ធនាគារចិន ប្រចាំទីក្រុងហុងកុង*

នាថ្ងៃពុធ ១៥រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យគណៈប្រតិភូជាន់ខ្ពស់ធនាគារចិន ដឹកនាំដោយ**លោក** Sun Yu នាយកប្រតិបត្តិ ធនាគារចិន ប្រចាំទីក្រុងហុងកុង ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ ជំនួបនេះមានគោលបំណងឱ្យគណៈប្រតិភូធនាគារចិន បានស្វែងយល់ពីសក្តានុពលវិនិយោគថ្មីៗក្នុងវិស័យហិរញ្ញវត្ថុកម្ពុជា និងឱកាសក្នុងការពង្រីកប្រតិបត្តិការថែមទៀត។ ក្នុងជំនួបនេះ លោក Sun Yu បានជម្រាបជូនពីវឌ្ឍនភាពល្អនៃប្រតិបត្តិការរបស់ធនាគារចិននាពេលកន្លងមក និងបានបញ្ជាក់ពីការប្តេជ្ញារបស់ភាទុនិក ក្នុងការបន្តចូលរួមអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជាឱ្យបានកាន់តែប្រសើរថែមទៀត ដោយអនុវត្តតាមបទប្បញ្ញត្តិនានាឱ្យបានខ្ជាប់ខ្ជួន។ លើសពីនេះ លោកក៏បានលើកឡើងពីការសិក្សាអំពីលទ្ធភាពក្នុងការដាក់ឱ្យដំណើរការឧបករណ៍ហិរញ្ញវត្ថុថ្មីៗ និងការជំរុញការប្រើប្រាស់ប្រាក់រៀលសម្រាប់ទូទាត់ក្នុងប្រតិបត្តិការហិរញ្ញវត្ថុឱ្យបានកាន់តែទូលំទូលាយថែមទៀត។ ជាការឆ្លើយតប លោកជំទាវទេសាភិបាលបានស្វាគមន៍ចំពោះគម្រោងពង្រីកប្រតិបត្តិការនៅកម្ពុជា និងបានលើកឡើងពីអាទិភាពក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់និងស្ថិរភាពហិរញ្ញវត្ថុ សំដៅចូលរួមគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ បន្ថែមលើនេះ លោកជំទាវក៏បានមានប្រសាសន៍អំពីទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា ដោយបានរំលេចពីសក្តានុពល និងកត្តាប្រឈមមួយចំនួនពាក់ព័ន្ធនឹងភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយតំបន់និងសកលលោក និងការកើនឡើងតម្លៃប្រេងលើទីផ្សារអន្តរជាតិជាដើម។

## លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

### ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យក្រុមការងារវិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ (IBF) ដឹកនាំដោយលោក វ័ត្ន សោភ័ណ ប្រធានសមាគមធនាគារនៅកម្ពុជា (ABC) ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍នានា



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*



*លោក វ័ត្ន សោភ័ណ ប្រធានសមាគមធនាគារនៅកម្ពុជា (ABC)*

នាថ្ងៃចន្ទ ៥កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យក្រុមការងារវិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ (IBF) ដឹកនាំដោយ**លោក វ័ត្ន សោភ័ណ** ប្រធានសមាគមធនាគារនៅកម្ពុជា (ABC) ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍នានាអំពីដំណើរការកម្មវិធីសិក្សាវិញ្ញាបនបត្រ Accredited Director Program (ADP) នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ ក្នុងជំនួបនេះ លោក វ័ត្ន សោភ័ណ បានបង្ហាញពីគោលបំណងនៃកម្មវិធីសិក្សា ADP ដែលមានគោលដៅលើកកម្ពស់អភិបាលកិច្ចសាជីវកម្មនៅក្នុងក្រុមហ៊ុន ជាពិសេសក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ លោកក៏បានជម្រាបជូនអំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីនេះ និងស្នើសុំអនុសាសន៍បន្ថែម ដើម្បីពង្រឹងគុណភាពកម្មវិធីឱ្យកាន់តែប្រសើរ និងមានភាពសមស្របតាមនិន្នាការវិវត្តន៍នៃវិស័យធនាគារនៅកម្ពុជា។ ជាការឆ្លើយតប លោកជំទាវទេសាភិបាល បានបង្ហាញក្តីសោមនស្សចំពោះការវិវត្តរបស់ IBF នាពេលកន្លងមក ដែលស្របតាមគោលបំណងក្នុងការអភិវឌ្ឍមូលធនមនុស្សក្នុងវិស័យធនាគារ ទាំងផ្នែកបរិមាណ និងគុណភាព។ ជាមួយគ្នានេះ លោកជំទាវបានបង្ហាញការគាំទ្រចំពោះកម្មវិធីសិក្សា ADP នេះ និងផ្តល់អនុសាសន៍មួយចំនួន ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីបន្ថែមទៀត ព្រមទាំងលើកទឹកចិត្តឱ្យវិទ្យាស្ថាន IBF ពង្រឹងកិច្ចសហការជិតស្និទ្ធជាមួយវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ (IBS) ផងដែរ។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា និងលោកជំទាវ ខៀវ ស៊ីណា ជា ចាន់តូ អញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់វិទ្យាល័យ ជា ចាន់តូ



នាថ្ងៃព្រហស្បតិ៍ ៣កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៦ **លោកជំទាវ ខៀវ ស៊ីណា ជា ចាន់តូ** និង**លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់វិទ្យាល័យ ជា ចាន់តូ នៅស្រុកសន្ទុក ខេត្តកំពង់ធំ ដោយមានការចូលរួមពីអាជ្ញាធរស្រុក-ឃុំ គណៈគ្រប់គ្រងនៃបណ្ដាគ្រឹះស្ថានសិក្សា លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស ព្រមទាំងអាណាព្យាបាលជាច្រើនរូប។ វិទ្យាល័យ ជា ចាន់តូ ត្រូវបានបង្កើតឡើង ស្របតាមឆន្ទៈរបស់**ឯកឧត្តម ជា ចាន់តូ** ទេសាភិបាលកិត្តិយស ធនាគារជាតិនៃកម្ពុជា ក្នុងការចូលរួមចំណែកអភិវឌ្ឍវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាកសាងមូលធនមនុស្ស តាមរយៈការផ្តល់ឱកាសដល់សិស្សានុសិស្សនៅតាមទីជនបទឱ្យទទួលបានកម្មវិធីសិក្សាប្រកបដោយគុណភាពខ្ពស់។





# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា ១ខ្នង និងអគារបណ្ណាល័យ ១ខ្នង នៅវិទ្យាល័យ ជា ស៊ីម កំពង់ថ្ម ស្ថិតក្នុងឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ





នាថ្ងៃសៅរ៍ ៤រោចខែផល្គុន ឆ្នាំម្សាញ់ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា ១ខ្នង មាន២ជាន់ ស្មើនឹង ១២បន្ទប់ និងអគារបណ្ណាល័យ ១ខ្នង នៅវិទ្យាល័យ ជា ស៊ីម កំពង់ថ្ម ស្ថិតក្នុងឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ពិធីនេះក៏មានវត្តមានចូលរួមពីថ្នាក់ដឹកនាំរដ្ឋបាលស្រុកបារាយណ៍ លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋជាច្រើនរូប។ ក្នុងឱកាសនេះ លោកជំទាវបានមានប្រសាសន៍ ពីការយក់ចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍមូលធនមនុស្ស និងបានចាត់ទុកជាអាទិភាពសម្រាប់អនុវត្តនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ នៅគ្រប់ដំណាក់កាល។ លោកជំទាវបន្ថែមថា ការកសាងនិងដាក់ឱ្យដំណើរការសមិទ្ធផលថ្មីៗខាងលើនេះ បង្ហាញពីការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ក្នុងការចូលរួមក្នុងដំណើរការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា ក៏ដូចជាការកសាងធនធានមនុស្សប្រកបដោយចំណេះដឹងគ្រប់គ្រាន់ស្របតាមគោលនយោបាយអាទិភាពរបស់រាជរដ្ឋា-ភិបាលកម្ពុជា។ នាឱកាសនោះ លោកជំទាវទេសាភិបាលបានលើកទឹកចិត្តឱ្យសិស្សានុសិស្សទាំងអស់ខិតខំសិក្សារៀនសូត្រឱ្យបានខ្លាំងក្លា និងបានអំពាវនាវឱ្យមាតាបិតានិងអាណាព្យាបាលចូលរួមជំរុញនិងគាំទ្រការសិក្សារបស់សិស្សានុសិស្ស ដើម្បីរួមគ្នាបង្កើនធនធានមនុស្សប្រកបដោយសក្តានុពល សម្រាប់ចូលរួមអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើននាពេលខាងមុខ។

# អត្រាប្តូរប្រាក់ប្រចាំខែ

(អត្រាប្តូរចុងខែ)

| ចុងខែ | អត្រាទីផ្សារ | | | | | អត្រាផ្លូវការ | | | គម្លាតអត្រាមធ្យម | |
|---|---|---|---|---|---|---|---|---|---|---|
| | ទិញ | លក់ | មធ្យម | ប្រែប្រួលប្រចាំខែ | | មធ្យម | ប្រែប្រួលប្រចាំខែ | | អត្រាផ្លូវការ-ទីផ្សារ | |
| | | | | +/- | % | | +/- | % | +/- | % |
| **២០២៣** | | | | | | | | | | |
| កក្កដា | ៤.១២៤ | ៤.១៣៤ | ៤.១២៩ | -២ | -0,0៥ | ៤.១៣០ | 0 | 0,00 | -១ | -0,0២ |
| សីហា | ៤.១៥១ | ៤.១៦១ | ៤.១៥៦ | ២៧ | 0,៦៥ | ៤.១៥៨ | ២៨ | 0,៦៨ | -៣ | -0,0៦ |
| កញ្ញា | ៤.១១៩ | ៤.១៣០ | ៤.១២៥ | -៣២ | -0,៧៧ | ៤.១២២ | -៣៦ | -0,៨៧ | ៣ | 0,0៦ |
| តុលា | ៤.១២៩ | ៤.១៣៧ | ៤.១៣៣ | ១០ | 0,២៤ | ៤.១៣៥ | ១៣ | 0,៣២ | ២ | 0,0៥ |
| វិច្ឆិកា | ៤.១១៣ | ៤.១២៣ | ៤.១១៨ | -១៦ | -0,៣៩ | ៤.១១៥ | -២០ | -0,៤៨ | ២ | 0,0៤ |
| ធ្នូ | ៤.0៨0 | ៤.0៩0 | ៤.0៨៥ | -៣៣ | -0,៨0 | ៤.0៨៥ | -៣0 | -0,៧៣ | 0 | 0,00 |
| **២០២៤** | | | | | | | | | | |
| មករា | ៤.0៨0 | ៤.0៩១ | ៤.0៨៦ | 0 | -0,៥៤ | ៤.0៨៣ | -២ | -0,0៥ | -១ | 0,0២ |
| កុម្ភៈ | ៤.0៦៤ | ៤.0៧៣ | ៤.0៦៩ | -១៦ | 0,៣៥ | ៤.0៦៩ | -១៤ | -0,៣៤ | ២ | 0,0៤ |
| មីនា | ៤.0៤0 | ៤.0៤៩ | ៤.0៤៥ | -២៤ | -0,២៧ | ៤.0៤១ | -២៨ | -0,៦៩ | ៤ | 0,0៩ |
| មេសា | ៤.0៤៧ | ៤.0៦0 | ៤.0៥៤ | -៧ | -0,១៧ | ៤.0៤៩ | -៨ | -0,១៩ | ៤ | 0,0៩ |
| ឧសភា | ៤.0៧៥ | ៤.0៨៥ | ៤.0៨0 | -២៨ | -0,៦៩ | ៤.0៧៧ | -២៨ | -0,៦៩ | -១ | -0,0១ |
| មិថុនា | ៤.១0៩ | ៤.១២0 | ៤.១១៤ | -៣៤ | -0,៨៣ | ៤.១១៣ | -៣៦ | -0,៨៨ | ៤ | 0,១0 |
| កក្កដា | ៤.១0៦ | ៤.១១៦ | ៤.១១១ | ៣ | 0,0៧ | ៤.១0៩ | ៤ | 0,0៩ | ២ | 0,0៥ |
| សីហា | ៤.0៨៧ | ៤.0៩៨ | ៤.0៩៣ | ១៨ | 0,៤៣ | ៤.0៩១ | ១៨ | 0,៤៣ | ៧ | 0,១៦ |
| កញ្ញា | ៤.0៥៩ | ៤.0៧១ | ៤.0៦៥ | ២៨ | 0,៦៨ | ៤.0៦៣ | ២៨ | 0,៦៨ | ៤ | 0,១១ |
| តុលា | ៤.១៥៩ | ៤.0៧0 | ៤.0៦៥ | 0 | 0,00 | ៤.0៦១ | -២ | -0,0៤ | ៤ | 0,១១ |
| វិច្ឆិកា | ៤.0៤0 | ៤.0៥២ | ៤.0៣៦ | -២៩ | -0,៧១ | ៤.0៤៥ | -១៦ | -0,៣៩ | ៥ | 0,១១ |
| ធ្នូ | ៤.0២0 | ៤.0៣១ | ៤.0២៥ | -១១ | -0,២៧ | ៤.0២៣ | -២២ | -0,៥៤ | ៣ | 0,0៦ |
| **២០២៥** | | | | | | | | | | |
| មករា | ៤.0១៨ | ៤.0៣២ | ៤.0២៥ | 0 | 0,00 | ៤.0២៤ | ១ | 0,0២ | ២ | 0,0៥ |
| កុម្ភៈ | ៤.00៨ | ៤.0២0 | ៤.0១៤ | -១១ | -0,២៧ | ៤.0១១ | -១៣ | -0,៣២ | ៣ | 0,0៧ |
| មីនា | ៣.៩៩៦ | ៤.00៨ | ៤.00២ | -១២ | -0,២៩ | ៤.000 | -១១ | -0,២៧ | ៤ | 0,0៣ |
| មេសា | ៤.000 | ៤.0១១ | ៤.00៦ | ៤ | 0,0៩ | ៤.00៣ | ៣ | 0,១0 | ៣ | 0,១0 |
| ឧសភា | ៤.00២ | ៤.0១២ | ៤.00៧ | ១ | 0,0៤ | ៤.00៥ | ២ | 0,0៦ | ១ | 0,0៥ |
| មិថុនា | ៤.00៨ | ៤.0១៩ | ៤.0១៣ | ៤ | 0,១៥ | ៤.0១0 | ៥ | 0,១៣ | 0,២ | 0,0៣ |
| កក្កដា | ៤.00៦ | ៤.0១៦ | ៤.0១១ | 0 | 0,00 | ៤.0១0 | ១ | 0,0១ | ១ | 0,0៣ |
| សីហា | ៤.00៤ | ៤.0១៣ | ៤.00៨ | -៣ | -0,0៦ | ៤.00៧ | -៣ | -0,0៦ | ២ | 0,0៥ |
| កញ្ញា | ៤.00៥ | ៤.0១៥ | ៤.0១0 | ២ | 0,0៤ | ៤.00៨ | ១ | 0,0៤ | ៣ | 0,0៦ |
| តុលា | ៤.0១៧ | ៤.0២៨ | ៤.0២៣ | ១២ | 0,៣១ | ៤.0២១ | ១៣ | 0,៣0 | ២,៩ | 0,0៧ |
| វិច្ឆិកា | ៤.0១0 | ៤.0២0 | ៤.0១៥ | -៨ | -0,២0 | ៤.0១៣ | -៨ | -0,១៩ | ៣,៦ | 0,0៩ |
| ធ្នូ | ៤.00៨ | ៤.0១៨ | ៤.0១៣ | -២ | 0,0៤ | ៤.0១១ | -២ | -0,0៤ | ៣ | 0,0៧ |
| **២០២៦** | | | | | | | | | | |
| មករា | ៤.0២១ | ៤.0៣២ | ៤.0២៦ | ១៣ | 0,៣៣ | ៤.0២៤ | ១៣ | 0,៣៣ | ៣ | 0,0៦ |
| កុម្ភៈ | ៤.0២១ | ៤.0៣២ | ៤.0២៦ | 0 | 0,00 | ៤.0២៤ | 0 | 0,00 | ៤ | 0,១0 |
| មីនា | ៤.00៨ | ៤.0១៨ | ៤.0១៣ | -១៣ | -0,៣៣ | ៤.0១0 | -១៤ | -0,៣៣ | ៥ | 0,១១ |

# MONTHLY EXCHANGE RATE

(End-Month)

| End month | Parallel Market Rate | | | | | Official Exchange Rate | | | Spread | |
|---|---|---|---|---|---|---|---|---|---|---|
| | Purchase | Sale | Midpoint | Monthly Change | | Midpoint | Monthly Change | | Official-Market | |
| | | | | +/- | % | | +/- | % | +/- | % |
| **2023** | | | | | | | | | | |
| July | 4,124 | 4,134 | 4,129 | -2 | -0.05 | 4,130 | 0 | 0.00 | -1 | -0.02 |
| August | 4,151 | 4,161 | 4,156 | 27 | 0.65 | 4,158 | 28 | 0.68 | -3 | -0.06 |
| September | 4,119 | 4,130 | 4,125 | -32 | -0.77 | 4,122 | -36 | -0.87 | 3 | 0.06 |
| October | 4,129 | 4,137 | 4,133 | 10 | 0.24 | 4,135 | 13 | 0.32 | 2 | 0.05 |
| November | 4,113 | 4,123 | 4,118 | -16 | -0.39 | 4,115 | -20 | -0.48 | 2 | 0.04 |
| December | 4,080 | 4,090 | 4,085 | -33 | -0.80 | 4,085 | -30 | -0.73 | 0 | 0.00 |
| **2024** | | | | | | | | | | |
| January | 4,080 | 4,091 | 4,086 | 0.0 | 0.00 | 4,083 | -2 | -0.05 | -1 | -0.02 |
| February | 4,064 | 4,073 | 4,069 | -16.0 | -0.39 | 4,069 | -14 | -0.34 | 2 | 0.04 |
| March | 4,040 | 4,049 | 4,045 | -24.0 | -0.59 | 4,041 | -28 | -0.69 | 4 | 0.09 |
| April | 4,047 | 4,060 | 4,054 | -7 | -17 | 4,049 | -8 | -0.19 | 4 | 0.09 |
| May | 4,075 | 4,085 | 4,080 | -28 | -69 | 4,077 | -28 | -0.69 | -1 | -0.01 |
| June | 4,109 | 4,120 | 4,114 | -34 | -83 | 4,113 | -36 | -0.88 | 4 | -0.10 |
| July | 4,106 | 4,116 | 4,111 | 3 | 0.07 | 4,109 | 4 | 0.09 | 2 | 0.05 |
| August | 4,087 | 4,098 | 4,093 | -18 | -0.43 | 4,091 | -18 | -0.43 | 7 | 0.16 |
| September | 4,059 | 4,071 | 4,065 | -28 | -0.68 | 4,063 | -28 | -0.68 | 4 | 0.11 |
| October | 4,059 | 4,070 | 4,065 | 0 | 0.00 | 4,061 | -2 | -0.04 | 4 | 0.11 |
| November | 4,040 | 4,052 | 4,036 | -29 | -0.71 | 4,045 | -16 | -0.39 | 5 | 0.11 |
| December | 4,020 | 4,031 | 4,025 | -11 | -0.27 | 4,023 | -22 | -0.54 | 3 | 0.06 |
| **2025** | | | | | | | | | | |
| January | 4,018 | 4,032 | 4,025 | 0 | 0.00 | 4,024 | 1 | 0.02 | 2 | 0.05 |
| February | 4,008 | 4,020 | 4,014 | -11 | -0.27 | 4,011 | -13 | -0.32 | 3 | 0.07 |
| March | 3,996 | 4,008 | 4,002 | -12 | -0.29 | 4,000 | -11 | -0.27 | 4 | 0.03 |
| April | 4,000 | 4,011 | 4,006 | 4 | 0.09 | 4,003 | 3 | 0.10 | 3 | 0.10 |
| May | 4,002 | 4,012 | 4,007 | 1 | 0.04 | 4,005 | 2 | 0.06 | 1 | 0.05 |
| June | 4,008 | 4,019 | 4,013 | 4 | 0.15 | 4,010 | 5 | 0.13 | 0.2 | 0.03 |
| July | 4,006 | 4,016 | 4,011 | 0 | 0.00 | 4,010 | 1 | 0.01 | 1 | 0.03 |
| August | 4,004 | 4,013 | 4,008 | -3 | -0.06 | 4,007 | -3 | -0.06 | 2 | 0.05 |
| September | 4,005 | 4,015 | 4,010 | 2 | 0.04 | 4,008 | 1 | 0.04 | 3 | 0.06 |
| October | 4,017 | 4,028 | 4,023 | 12 | 0.31 | 4,021 | 13 | 0.30 | 2.9 | 0.07 |
| November | 4,010 | 4,020 | 4,015 | -8 | -0.20 | 4,013 | -8 | -0.19 | 3.6 | 0.09 |
| December | 4,008 | 4,018 | 4,013 | -2 | 0.04 | 4,011 | -2 | -0.04 | 3 | 0.07 |
| **2026** | | | | | | | | | | |
| January | 4,021 | 4,032 | 4,026 | 13 | 0.33 | 4,024 | 13 | 0.33 | 3 | 0.06 |
| February | 4,021 | 4,032 | 4,026 | 0 | 0.00 | 4,024 | 0 | 0.00 | 4 | 0.10 |
| March | 4,008 | 4,018 | 4,013 | -13 | -0.33 | 4,010 | -14 | -0.33 | 5 | 0.11 |

## ប្រាក់បញ្ញើនៅធនាគារទទួលប្រាក់បញ្ញើ និងបម្រែបម្រួលប្រចាំខែ

| | មករា-២៦ | | កុម្ភៈ-២៦ | | មីនា-២៦ | |
|---|---|---|---|---|---|---|
| | ប៊ីលានរៀល | % | ប៊ីលានរៀល | % | ប៊ីលានរៀល | % |
| **ប្រាក់បញ្ញើជារៀល** | | | | | | |
| ប្រាក់បញ្ញើចរន្ត | ៦.៤៣៧,៨ | ០,៥ | ៦.៦០៩,៩ | ២,៧ | ៦.៦១៧,៨ | ០,១ |
| ប្រាក់បញ្ញើសន្សំ | ៧.៧៧៥,៣ | ៧,៩ | ៨.០០៩,៥ | ៣,០ | ៧.៦៥៧,៥ | -៤,៤ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១៦.៨២៤,៨ | ១,៣ | ១៦.៨២៣,៥ | ០,០ | ១៦.៥៤៣,១ | -១,៧ |
| ប្រាក់បញ្ញើផ្សេងៗ | ១៦៩,៨ | -២,០ | ១៨០,០ | ៦,០ | ១៥៧,១ | -១២,៧ |
| **សរុប** | **៣១.២០៧,៩** | **២,៧** | **៣១.៦២២,៩** | **១,៣** | **៣០.៩៧៥,៥** | **-២,០** |
| **ប្រាក់បញ្ញើជារូបិយប័ណ្ណ** | | | | | | |
| ប្រាក់បញ្ញើចរន្ត | ៣៧.៧០៧,៨ | -៧,០ | ៣៧.៨១៧,៩ | ០,៣ | ៣៩.៤១៨,២ | ៤,២ |
| ប្រាក់បញ្ញើសន្សំ | ៧១.២០៦,៣ | ៣,៤ | ៧១.២៧០,៩ | ០,១ | ៧០.៥៤៧,៥ | -១,០ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១១៦.២៥៧,៩ | -០,២ | ១១៤.៤៦០,៤ | -១,៥ | ១១១.៣៥៩,៥ | -២,៧ |
| ប្រាក់បញ្ញើផ្សេងៗ | ១.៣៥២,៤ | ០,៤ | ១.៣២៥,៣ | -២,០ | ១.៥០៧,៤ | ១៣,៧ |
| **សរុប** | **២២៦.៥២៤,៤** | **-០,៣** | **២២៤.៨៧៤,៥** | **-០,៧** | **២២២.៨៣២,៦** | **-០,៩** |
| **សរុបរួម** | **២៥៧.៧៣២,៣** | **០,០** | **២៥៦.៤៩៧,៤** | **-០,៥** | **២៥៣.៨០៨,១** | **-១,០** |

## DEPOSITS WITH DEPOSIT MONEY BANKS AND MONTHLY CHANGE

| | January-26 | | February-26 | | March-26 | |
|---|---|---|---|---|---|---|
| | KHR. Billion | % | KHR. Billion | % | KHR. Billion | % |
| DEPOSITS IN KHR. | | | | | | |
| Demand deposits | 6,437.8 | 0.5 | 6,609.9 | 2.7 | 6,617.8 | 0.1 |
| Savings deposits | 7,775.3 | 7.9 | 8,009.5 | 3.0 | 7,657.5 | -4.4 |
| Fixed deposits | 16,824.8 | 1.3 | 16,823.5 | 0.0 | 16,543.1 | -1.7 |
| Others | 169.8 | -2.0 | 180.0 | 6.0 | 157.1 | -12.7 |
| **Total** | **31,207.9** | **2.7** | **31,622.9** | **1.3** | **30,975.5** | **-2.0** |
| DEPOSITS IN FOREIGN CURRENCY | | | | | | |
| Demand deposits | 37,707.8 | -7.0 | 37,817.9 | 0.3 | 39,418.2 | 4.2 |
| Savings deposits | 71,206.3 | 3.4 | 71,270.9 | 0.1 | 70,547.5 | -1.0 |
| Fixed deposits | 116,257.9 | -0.2 | 114,460.4 | -1.5 | 111,359.5 | -2.7 |
| Others | 1,352.4 | 0.4 | 1,325.3 | -2.0 | 1,507.4 | 13.7 |
| **Total** | **226,524.4** | **-0.3** | **224,874.5** | **-0.7** | **222,832.6** | **-0.9** |
| **GRAND TOTAL** | **257,732.3** | **0.0** | **256,497.4** | **-0.5** | **253,808.1** | **-1.0** |

## ឥណទានផ្តល់ដោយគ្រឹះស្ថានហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើតាមវិស័យ

| | មករា-២៦ | | កុម្ភៈ-២៦ | | មីនា-២៦ | |
|---|---|---|---|---|---|---|
| | ប៊ីលានរៀល | % | ប៊ីលានរៀល | % | ប៊ីលានរៀល | % |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២៣.០៦០.១ | -០,១ | ២២.៩៨៦.១ | -០,៣ | ២៣.០៦៦.៩ | ០,៤ |
| ឧស្សាហកម្មរ៉ែ | ១.៣៧០,៣ | -០,៥ | ១.៣៨៧,៧ | ១,៣ | ១.៣២៧,៧ | -១,១ |
| កម្មន្តសាលកម្ម | ១០.៥៥៨.៨ | -១,៨ | ១០.៣៦០.៩ | -១,៩ | ១០.៣៩៨.៦ | ០,៤ |
| ការផ្គត់ផ្គង់សេវាសាធារណៈ | ៤.៥៦៤,៨ | ១,៦ | ៤.៥១៣,៩ | -១,១ | ៤.៧៧៤,២ | ៥,៨ |
| សំណង់ | ២៥.២៨១.០ | ០,១ | ២៤.១៣៦.៩ | -៤,៥ | ២៤.៤០០.១ | ១,១ |
| ការជួញដូរដុំ | ២០.៤៣៦,១ | -១,៥ | ២០.២១៥,៨ | -១,១ | ២០.៥៩៩,៥ | ១,៩ |
| ការជួញដូររាយ | ៤០.៣៤៤,៩ | -១,៤ | ៤០.២៦០,៤ | -០,២ | ៤០.៧៥៣,៨ | ១,២ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ១០.០០៤,១ | -១,៣ | ១០.០៣៧,២ | ០,៣ | ១០.០១៨,៦ | -០,២ |
| សិល្បៈ និងការកម្សាន្ត | ៣២៣,២ | -២,៧ | ៣២៤,៨ | ០,៥ | ៣២៤,៣ | -០,១ |
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ៦.៣១៧,៧ | -៤,៣ | ៦.០៣០,៨ | -៤,៥ | ៥.៨២២,៤ | -៣,៥ |
| ដឹកជញ្ជូន និងស្តុកបណ្តោះអាសន្ន | ៦.៧៦៥,០ | ០,៩ | ៦.៧១២,៥ | -០,៨ | ៦.៨៤៣,៨ | ២,០ |
| បណ្តាញព័ត៌មាននិងទូរគមនាគមន៍ | ៩៥៧,០ | -២,៥ | ៩៦៥,៥ | ០,៩ | ៩៤៨,៨ | -១,៧ |
| អាជីវកម្មជួលនិងភតិសន្យា (មិនរាប់បញ្ចូលភតិសន្យានិងការជួលអចលនទ្រព្យ) | ៣.១០៦,៣ | -៣,២ | ៣.០៩៨,០ | -០,៣ | ៣.១១៧,៩ | ០,៦ |
| ការជួញដូរអចលនទ្រព្យ | ៥៣.៩៨៣,៩ | -១,៥ | ៥២.៩៦៨,៥ | -១,៩ | ៥២.៨០៤,៧ | -០,៣ |
| ការអប់រំ | ៨៨៦,៩ | -០,៦ | ៨៧០,៩ | -១,៨ | ៨៦៩,៧ | -០,១ |
| សុខភាព និងការងារសង្គម | ១.៤២៦,៧ | -៥,៨ | ១.៤៣១,៥ | ០,៣ | ១.៤៣៤,៨ | ០,២ |
| ការឱ្យខ្ចីជាបុគ្គល | ២៣.៣៨២,៧ | ១,២ | ២៣.៤៦៩,៧ | ០,៤ | ២៣.៦៣៤,០ | ០,៧ |
| ការឱ្យខ្ចីតាមប័ណ្ណឥណទាន | ១.១៩៩,៥ | ០,៧ | ១.១៩៨,០ | -០,១ | ១.១៧៤,៤ | ១,៤ |
| ការឱ្យខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន | ២៥.៧៦៣,៦ | ១,២ | ២៥.៨៧៥,៧ | ០,៤ | ២៦.០៦៨,៦ | ០,៧ |
| **ឥណទានផ្សេងៗ** | **១២.៩៥២,០** | **-២,៦** | **១២.៩៥៩,១** | **០,១** | **១៣.១៨១,៦** | **១,៧** |
| **សរុបឥណទានដុល** | **២៤៨.១០២,៥** | **-១,០** | **២៤៥.១៣៦,២** | **-១,២** | **២៤៦.៨០១,១** | **០,៧** |

# CREDIT GRANTED BY DEPOSITORY INSTITUTIONS CLASSIFIED BY ECONOMIC SECTOR

| | January-26 | | February-26 | | March-26 | |
|---|---|---|---|---|---|---|
| | KHR. Billion | # | KHR. Billion | # | KHR. Billion | # |
| Agriculture, Forestry and Fishing | 23,060.1 | -0.1 | 22,986.1 | -0.3 | 23,066.9 | 0.4 |
| Mining and Quarrying | 1,370.3 | -0.5 | 1,387.7 | 1.3 | 1,372.7 | -1.1 |
| Manufacturing | 10,558.8 | -1.8 | 10,360.9 | -1.9 | 10,398.6 | 0.4 |
| Utilities | 4,564.8 | 1.6 | 4,513.9 | -1.1 | 4,774.2 | 5.8 |
| Construction | 25,281.0 | 0.1 | 24,136.9 | -4.5 | 24,400.1 | 1.1 |
| Wholesale Trade | 20,436.1 | -1.5 | 20,215.8 | -1.1 | 20,599.5 | 1.9 |
| Retail Trade | 40,344.9 | -1.4 | 40,260.4 | -0.2 | 40,753.8 | 1.2 |
| Accommodation and Food Service Activities | 10,004.1 | -1.3 | 10,037.2 | 0.3 | 10,018.6 | -0.2 |
| Arts, entertainment and recreation | 323.2 | -2.7 | 324.8 | 0.5 | 324.3 | -0.1 |
| Financial and Insurance Activities | 6,317.7 | -4.3 | 6,030.8 | -4.5 | 5,822.4 | -3.5 |
| Transport and Storage | 6,765.0 | 0.9 | 6,712.5 | -0.8 | 6,843.8 | 2.0 |
| Information and Communications | 957.0 | -2.5 | 965.5 | 0.9 | 948.8 | -1.7 |
| Rental and Operational Leasing Activities | 3,106.3 | -3.2 | 3,098.0 | -0.3 | 3,117.9 | 0.6 |
| Real Estate Activities | 53,983.9 | -1.5 | 52,968.5 | -1.9 | 52,804.7 | -0.3 |
| Education | 886.9 | -0.6 | 870.9 | -1.8 | 869.7 | -0.1 |
| Human health and social work activities | 1,426.7 | -5.8 | 1,431.5 | 0.3 | 1,434.8 | 0.2 |
| Personal Lending | 23,382.7 | 1.2 | 23,469.7 | 0.4 | 23,634.0 | 0.7 |
| Credit Card | 1,159.5 | 0.7 | 1,158.0 | -0.1 | 1,174.4 | 1.4 |
| Mortgages, Owner-Occupied Housing only | 25,763.6 | 1.2 | 25,875.7 | 0.4 | 26,068.6 | 0.7 |
| **OTHER LENDING** | **12,952.0** | **-2.6** | **12,959.1** | **0.1** | **13,181.6** | **1.7** |
| **TOTAL GROSS LOAN** | **248,102.5** | **-1.0** | **245,136.2** | **-1.2** | **246,801.1** | **0.7** |

# ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអង្គការមិនមែនរដ្ឋាភិបាល

| | មករា-២៦ | កុម្ភៈ-២៦ | មីនា-២៦ |
|---|---|---|---|
| ចំនួនការិយាល័យកណ្តាល និងសាខា | ៨៩២ | ៨៩០ | ៧៤០ |
| ចំនួនអ្នកស្នើសុំឥណទាន | ១.៦៧១.៦៥០ | ១.៦៧១.៤៨៣ | ១.៤៥៣.៦៩១ |
| ប្រាក់កម្ចី (គិតជាប៊ីលានរៀល) | ២៣.៥៤៩ | ២៣.៦៥៥ | ២១.១៩១ |
| អត្រាការប្រាក់ប្រចាំខែ | ១,០%-១,៤% | ១,០%-១,៤% | ១,០%-១,៤% |
| អត្រាការប្រាក់ប្រចាំឆ្នាំ | ១២,៣%-១៦,៨% | ១២,៥%-១៦,៩% | ១២,៤%-១៦,៩% |

## CREDIT GRANTED BY MICRO-FINANCE INSTITUTIONS AND NON-GOVERNMENT ORGANIZATIONS

| | Januray-26 | February-26 | March-26 |
|---|---|---|---|
| Number of Head Office and Branches | 889 | 892 | 740 |
| Number of Borrowers | 1,672,964 | 1,671,650 | 1,453,691 |
| Loan Outstanding (In KHR Billion) | 23,276 | 23,549 | 21,191 |
| Monthly Interest Rate | 1.0%-1.4% | 1.0%-1.4% | 1.0%-1.4% |
| Annually Interest Rate | 12.4%-16.8% | 12.3%-16.8% | 12.4%-16.9% |

# ការផាត់ទាត់មូលប្បទានបត្រតាមរយៈសភាផាត់ទាត់

| | មករា-២៦ | កុម្ភៈ-២៦ | មីនា-២៦ | សរុប |
|---|---|---|---|---|
| **មូលប្បទានបត្រ ជាប្រាក់រៀល** | | | | |
| ចំនួនថ្ងៃផាត់ទាត់ | ២០ | ២០ | ២២ | ៦២ |
| ចំនួនមូលប្បទានបត្របានទូទាត់ | ២.២៨៨ | ២.៥៦៣ | ២.៨៥០ | ៧.៨០១ |
| ចំនួនទឹកប្រាក់សរុប (ប៊ីលានរៀល) | ១.៦០៤,៣ | ១.៥០៤,៣ | ២.០៦០,៤ | ៥.១៦៩ |
| ចំនួនមូលប្បទានបត្របានទូទាត់ក្នុងថ្ងៃ | ១១៩ | ១២៨ | ១៣០ | ១២៦ |
| ទឹកប្រាក់ជាមធ្យមប្រចាំថ្ងៃ (ប៊ីលានរៀល) | ៨០,២ | ៧៥,២ | ៩៣,៧ | ៨៣,៤ |
| ចំនួនមូលប្បទានបត្របញ្ជូនត្រឡប់ | ៦ | ១១ | ៤ | ២១ |
| ជាទឹកប្រាក់បញ្ជូនត្រឡប់សរុប (ប៊ីលានរៀល) | ០,៦៨ | ១,៦៧ | ១១,២១ | ១៣,៥៦ |
| **មូលប្បទានបត្រ ជាប្រាក់ដុល្លារអាមេរិក** | | | | |
| ចំនួនថ្ងៃផាត់ទាត់ | ២០ | ២០ | ២២ | ៦២ |
| ចំនួនមូលប្បទានបត្របានទូទាត់ | ៨០.៤៤២ | ៧៣.១០៩ | ៨៥.២៦១ | ២៣៨.៨១២ |
| ចំនួនទឹកប្រាក់សរុប (លានដុល្លារអាមេរិក) | ៤.៤២០,២ | ៣.៦៩២,៤ | ៥.២៣៨,៣ | ១៣.៣៥០,៩ |
| ចំនួនមូលប្បទានបត្របានទូទាត់ក្នុងថ្ងៃ | ៤.០២២ | ៣.៦៥៥ | ៣.៨៧៦ | ៣.៨៥២ |
| ទឹកប្រាក់ជាមធ្យមប្រចាំថ្ងៃ (លានដុល្លារអាមេរិក) | ២២១,០ | ១៨៤,៦ | ២៣៨,១ | ២១៥,៣ |
| ចំនួនមូលប្បទានបត្របញ្ជូនត្រឡប់ | ៥២១ | ៤៧៣ | ៥០៧ | ១.៥០១ |
| ទឹកប្រាក់បញ្ជូនត្រឡប់សរុប (លានដុល្លារអាមេរិក) | ៦១,៧ | ៤៦,៤ | ១២៧,៧ | ២៣៥,៨ |

## CHECKS CLEARING THROUGH CLEARING HOUSE

| | Jan-26 | Feb-26 | Mar-26 | Total |
|---|---|---|---|---|
| **KHR-DENOMINATED CHECKS CLEARING** | | | | |
| Number of Working Day | 22 | 20 | 22 | 62 |
| Number of Checks Cleared | 2,388 | 2,563 | 2,853 | 7,801 |
| Total Amount (In KHR Billion) | 1,640.3 | 1,504.3 | 2,060.4 | 5,169 |
| Number of Checks Cleared Per Day | 119 | 128 | 130 | 126 |
| Daily Average Amount (In KHR Billion) | 80.2 | 75.2 | 93.7 | 83.4 |
| Number of Checks Returned | 6 | 11 | 4 | 21 |
| Amounts of Checks Returned (In KHR Billion) | 0.68 | 1.67 | 11.21 | 13.56 |
| **USD-DENOMINATED CHECKS CLEARING** | | | | |
| Number of Working Day | 20 | 20 | 22 | 62 |
| Number of Checks Cleared | 80,442 | 73,109 | 85,261 | 238,261 |
| Total Amount (In USD Million) | 4,420.2 | 3,692.4 | 5,283.3 | 13,350.9 |
| Number of Checks Cleared Per Day | 4,022 | 3,655 | 3,876 | 3,852 |
| Daily Average Amount (In USD Million) | 221.0 | 184.6 | 238.1 | 215.3 |
| Number of Checks Returned | 521 | 473 | 507 | 1,501 |
| Amounts of Checks Returned (In USD Million) | 61.7 | 46.4 | 127.7 | 235.8 |

# ប្រព័ន្ធធនាគារកម្ពុជា (ខែកុម្ភៈ ឆ្នាំ២០២៦)

## ធនាគារជាតិនៃកម្ពុជា

### ៥៨ ធនាគារពាណិជ្ជ

**២៦ បង្កើតក្នុងស្រុក**

១ ព.ណ.ក្រៅប្រទេស
២ កម្ពុជាអាស៊ី
៣ កាណាឌីយ៉ា
៤ ធនាគារវឌ្ឍនៈ
៥ អេស៊ីលីដា
៦ ស្ថាបនា
៧ ប៊ូយ៉ុងខ្មែរ
៨ ភ្នំពេញពាណិជ្ជ
៩ ប្រៃសណីយ៍
១០ ឈីហ្វ
១១ អាយប៊ែង
១២ ជីបម៉ុង
១៣ អេស៊ា-ប៉ាស៊ីហ្វិក
១៤ អភិ.ជនបទ និងកសិ.
១៥ សហ. ធុនតូចនិងមធ្យម
១៦ ពាណិជ្ជ អាល់ហ្វា
១៧ អេសប៊ីអាយលីហ្វូរ
១៨ ធនាគារហត្ថា
១៩ រួយលី
២០ វីង
២១ អេចអេច
២២ អ្ហូវៀនថល
២៣ ប្រ៊ីដ
២៤ ស៊ីស៊ីយូ
២៥ ហេង ហ្វឹង
២៦ អាយភីយូ

**១១ សាខាបរទេស**

១ ធ.ពាណិជ្ជទី១
២ ធ.ក្រុងថៃ
៣ ធនាគារចិន
៤ ធនាគារមេហ្គា
៥ អាយស៊ីប៊ីស៊ី
៦ ធនាគារតៃវ៉ាន់
៧ ធនាគារបាងកក
៨ ធនាគារកសិកន
៩ ធនាគារមីហ្ស៊ូហូ
១០ ធ. វៀតណាម
១១ អ៊ិនដាសស្រៀល

**២១ បុត្តសម្ព័ន្ធ**

១ កម្ពុជាពាណិជ្ជ
២ សាធារណៈ
៣ មេយប៊ែង
៤ ជេ ត្រាស់ រ៉ូយ៉ាល់
៥ វឌ្ឍនៈអាស៊ី
៦ វិនិយោគ និងអភិ.
៧ ស៊ិនហានខ្មែរ
៨ អ អេច ប៊ី
៩ ស៊ីអាយ អឹមប៊ី
១០ សាខម ប៊ែង
១១ ហុងលីអ៊ុង
១២ ធនាគារកាថេ
១៣ សហពាណិជ្ជ
១៤ ហ្វីលីព
១៥ សៃហ្គន-ហាណូយ
១៦ ប្រេដប៊ែង
១៧ ឌីជីប៊ី
១៨ ធនាគារ អ៊ូរី
១៩ ធនាគារ អ៊ឹមប៊ី
២០ ខេប៊ីប្រាសាក់
២១ អេអឹមខេ

### ៧ ធនាគារឯកទេស

**៣ បង្កើតឡើងក្នុងស្រុក**

១ អានកូ
២ អេវើហ្គ្រស៍
៣ ដូនពេញ

**៤ ធនាគារបរទេស**

១ ភីអេចអែសអឹមអ៊ី
២ ខេប៊ី ដេហាន
៣ អ៊ីអន
៤ សាវធើន យៃភីថល

### ៥ ការិយាល័យតំណាង

១ ស្តង់ដារឆាទើរែត
២ ធ.វិ.អ.វៀតណាម
៣ ធ.ស៊ូមីតូម៉ូមីតស៊ុយ
៤ ធនាគារ សៀងហៃ
៥ អិចផត-អ៊ីមផត ប៊ែង

### ១៧៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ

**៤ ទទួលប្រាក់បញ្ញើ**

១ អម្រឹត ម.ក
២ អិល អូ អិល ស៊ី
៣ មហានគរ ម.ក

**៨៥ ផ្តល់ឥណទាន**

១ សីលានិធិ
២ វេលខម
៣ មាក់ស៊ីម៉ា
៤ ពលរដ្ឋរុងរឿង
៥ ណុងហឹប
៦ ហ្វាមើរ
៧ ហ្វីស
៨ វ៉ាយស៊ីភី
៩ សំរិទ្ធិស័ក
១០ ខេមា
១១ ខេមរៈ
១២ ប្រាយ៍ម
១៣ សូណាត្រា
១៤ ចម្រើន
១៥ អាក់ទីវភីភល
១៦ បាយ៉ន
១៧ បរិបូរណ៍
១៨ ឃ្វីន
១៩ ស៊ីធី
២០ អមតៈ
២១ សច្ចៈ
២២ អ្សូរ៉
២៣ និរន្តរ
២៤ ខ្មៃលតា
២៥ សេនជូរី
២៦ ប៊ីអេអឹមស៊ី
២៧ សិរីឧត្តម
២៨ សម្បត្តិ
២៩ ប៊ីអេនខេស៊ី
៣០ ប៊ែមប៊ូ
៣១ សហគ្រិនភាព
៣២ ឆាយលីស
៣៣ ធីប៊ីប៊ី
៣៤ រ៉ូយ៉ាល់
៣៥ សាន់នី
៣៦ ហ្វូណន
៣៧ សម្ព័ន្ធសហគ្រាស
៣៨ សាមគ្គី
៣៩ ខេមបូឌា ឡេប៊ី
៤០ ខេម ខាប់ភីថល
៤១ គង្គា យៃភីថល
៤២ ហ្វូតាបា
៤៣ អ៊ីខេមីតស៊ុ
៤៤ ម៉ាខ្មែរ
៤៥ សហការ
៤៦ ហ្គោលដិន
៤៧ ជោគជ័យ
៤៨ សប្បាយ
៤៩ ជេត យៃស
៥០ លីដ
៥១ អិល ប៊ី ភី
៥២ ប្រសិទ្ធភាព
៥៣ ធី & ហ្វ
៥៤ អនាគត
៥៥ ហ្វ្រូវ
៥៦ បៃតង
៥៧ មីយ៉ា
៥៨ ឡេង ណាវ៉ាត្រា
៥៩ វិថី
៦០ ទ្រព្យខ្ញុំ
៦១ ខ្មែរ
៦២ ភីជី
៦៣ ជេស៊ី
៦៤ ស៊ីអិមខេ
៦៥ រ៉ូល្យា
៦៦ អិលស៊ីអេច
៦៧ ហ្វាមីលី
៦៨ ប្រពៃ
៦៩ ស៊ិកធីស៊ិកស៍
៧០ ជីប៊ី
៧១ អេវើហ្គ្រីន
៧២ វ៉ាយអិលភី
៧៣ សារ៉ាត រុងរឿង
៧៤ មែងហ្គោ
៧៥ ខូវីច ម៉ាយក្រូហ្វាយ
៧៦ វិវឌ្ឍន៍ ហ្គោលឌិន
៧៧ សាយ ហូសថល
៧៨ សុខសាន្ត
៧៩ អេអិមហ្សេត
៨០ ជេកស៍
៨១ អ៊ីស្ត មីក្រូ ម.ក
៨២ វ៉ាហ្វូកូ
៨៣ អេច អេហ្វ ស៊ី
៨៤ រិច អ៊ែរីន្យូ

**៨៩ ឥណទានជនបទ**

១ ជូ ជីវ៉ន
២ គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ
៣ បវរ
៤ ពាយ័ព្យ
៥ សេន
៦ មិត្តភាព ហ្វាយនែន
៧ អិល អ៊ី ឌី អេ យៃភីថល
៨ ដៃគូ
៩ ព្រះខ័ន អភិវឌ្ឍន៍
១០ ក្រេប៉ូ ហ្វាយនែន
១១ វី.ភី ឌិច
១២ សិរីសួស្តី
១៣ ជ ម៉ុជីង
១៤ ហ៊ីគាន
១៥ កូនខ្មែរមង្គលហិរញ្ញវត្ថុ
១៦ មានជ័យ
១៧ ប្រសើរ
១៨ មាគ៌ា
១៩ ខេភីស៊ីអេ
២០ ដាកូ
២១ សំណាងប្រតិបត្តិការ
២២ ស្នាយល៍ យៃភីថល
២៣ គុណភាព
២៤ សំរិទ្ធិ ពេជ្រ
២៥ ប៊ី.វ៉ាយ.ជី
២៦ ឃ្វីក អមតៈ
២៧ អិលអេច
២៨ បៃតង
២៩ ជុំ សំណាង
៣០ ខេម
៣១ ឥណទាន អ៊ីហ្ស៊ី
៣២ មរតក អភិវឌ្ឍន៍
៣៣ កល្យាណ អភិវឌ្ឍន៍
៣៤ វីរៈបុត្រ
៣៥ ឥណទាន ជនបទខ្មែរ
៣៦ ផ្កាឈូក
៣៧ សុខសប្បាយ
៣៨ ខេ.ខេ.ស៊ី.អិម
៣៩ ប្រសិទ្ធិភាព
៤០ ហ្គូបល ឡៃនឌីង ពូ
៤១ អិល ឌី អេ
៤២ ឥណទាននារី
៤៣ ពិដោរ
៤៤ ស្កាយ ឡាយ
៤៥ គ្រួសារឥណទាន
៤៦ អមតៈរុងរឿង
៤៧ គន្ធាម
៤៨ សំបូរណ៍
៤៩ ទីបុត្តា
៥០ វ៉ាយស្មាត
៥១ អង្គរ ឆព្វណ្ណ
៥២ កាក់កប
៥៣ ព្រះច័ន្ទ
៥៤ អូណូ
៥៥ អេហ្វអេចអេហ្វ
៥៦ ខេមហ្វាន់ ប្រាថ្នា
៥៧ ម៉ាមេឌី
៥៨ វីរៈស័ក
៥៩ វ៉ាឆា
៦០ ឥណទានមូលដ្ឋាន
៦១ សម្របសម្រួល
៦២ ពិស្ណុកា
៦៣ ប្រាក
៦៤ លីជូ
៦៥ អេ.លី.អិល.ភី.អិល
៦៦ ពន្លឺស្នាមញញឹម
៦៧ មេត្តា
៦៨ អេហ្វធី យៃស
៦៩ រស្មីជ័យជំនះ
៧០ រីករាយ
៧១ ស៊ី.ខេ.អិល.អេស
៧២ យូនីត្រាស់
៧៣ គ្រីស្តាល់
៧៤ អេស ប៊ី អ៊ី
៧៥ អាខាបារ
៧៦ រិទ្ធី
៧៧ សមធម៌
៧៨ ផាតនើរ
៧៩ រាហ៊ូ
៨០ សុវណ្ណភូមិ សូសល
៨១ ធិតិមា
៨២ អេស.អិម.អ៊ី.អេស
៨៣ ផានីតដា
៨៤ អូខិនជិន
៨៥ វ៉ាយ ផ្លេស
៨៦ ហ៉ប ហ្វាន់
៨៧ មរកត
៨៨ វី ស៊ីវីស
៨៩ ឧដុង្គ

### សាខាធនាគារជាតិនៃកម្ពុជា

១ ភ្នំពេញ
២ កំពង់ចាម
៣ ព្រះសីហនុ
៤ សៀមរាប
៥ បាត់ដំបង
៦ បន្ទាយមានជ័យ
៧ ស្វាយរៀង
៨ កណ្តាល
៩ កំពត
១០ កំពង់ធំ
១១ ពោធិ៍សាត់
១២ កំពង់ស្ពឺ
១៣ កោះកុង
១៤ រតនៈគិរី
១៥ ព្រៃវែង
១៦ តាកែវ
១៧ កំពង់ឆ្នាំង
១៨ ព្រះវិហារ
១៩ ក្រចេះ
២០ ស្ទឹងត្រែង
២១ មណ្ឌលគិរី

### អាជីវកម្មផ្សេងៗ

**អាជីវកម្មប្តូរប្រាក់: ៣.៣៧៦**

ភ្នំពេញ: **៩១**
- អាជ្ញាប័ណ្ណ: ៣៣
- លិខិតអនុញ្ញាត: ៥៨

ខេត្ត: **៣.២៨៥**
- អាជ្ញាប័ណ្ណ: ៥
- លិខិតអនុញ្ញាត: ៣.២៨០

**១២ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ**

១ ទន្លេ ហ្វាយនែន
២ មេហ្គា លីស៊ីង
៣ សួស្តី ហ្វាយនែន
៤ ខេខេហ្វាន់ លីស៊ីង
៥ តូយ៉ូតា ស៊ុយស៊ូ ហ្វាយនែន
៦ ឆាយលីស រ៉ូយ៉ាល លីស៊ីង
៧ ខូម៉ាត់ស៊ុ លីស៊ីង
៨ គូបូតា លីស៊ីង
៩ អិល អូ ឌី
១០ អាយយែរ លីស៊ីង
១១ ហ្វរវើដ លីស៊ីង
១២ វី ស៊ីវីស លីស៊ីង

**៤ តតិយភាគី**

១ ក្រុមហ៊ុន Western Union
២ ក្រុមហ៊ុន Money Gram
៣ ក្រុមហ៊ុន Dandelion Payment
៤ ក្រុមហ៊ុន ណូវើស ថេកណូឡូជី

**៣០ គ្រឹះស្ថានផ្តល់សេវាទូទាត់**

១ ទ្រូ ម៉ាន់នី
២ លីហ្វរ ផេ ប្រូ
៣ ផាយផេ
៤ អេស៊ា យៃស
៥ ស៊ីធេល ហ្វាយនែនសល
៦ អាប៊ីត្រេរី ផេយ
៧ យូប៊ីល
៨ អ៊ីឌាល
៩ អាយផេ ៨៨
១០ បងឡូយ ផេម៉ិន
១១ ផានស៊ូ អ៊ិនធើណេសិនណល
១២ ហ្វូយ វ៉ន
១៣ អ៊ី-ម៉ាន់នី
១៤ ជ្រេហ្គនហ្វាយ
១៥ ដាយនៃមីក
១៦ តារាសាគរ ផេ
១៧ បៃ សេន ថេកណូឡូជី
១៨ អ៊ែរទ្រីណូ គ្លូបល
១៩ ផាវ៉ាហ្គន
២០ យេស អ៊ិននើវេសិន
២១ វ៉ន ផេ ម.ក
២២ លីន ផេ
២៣ យូ-ផេ
២៤ ស្តារផេ
២៥ ឡានតុន
២៦ គ្លីក ផេម៉ិន
២៧ សាន់ផេ
២៨ កៃ ហ្វូ តុង ផេម៉ិន
២៩ ផេយ៉ុន
៣០ ជីន ហុង ជិន

**១ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ**

១ ក្រេឌីតប្យូរ៉ូ (ខេមបូឌា)

# THE BANKING SYSTEM IN CAMBODIA (In February 2026)

## NATIONAL BANK OF CAMBODIA

### 58 COMMERCIAL BANKS

**26 Local Banks**

1. Foreign Trade
2. Cambodia Asia
3. Canadia
4. Vattanac
5. ACLEDA
6. Sathapana
7. Booyoung
8. PP Commercial
9. Cambodia Post
10. Chief
11. B.I.C
12. Chip Mong
13. Asia-Pacific
14. J Trust
15. Agricultural and Rural
16. SME Bank
17. Alpha Commercial
18. SBI Ly Hour
19. Ruili
20. Wing
21. Heng He
22. Oriental
23. Bridge Bank Plc.
24. CCU
25. Heng Feng
26. IPU SEA

**11 Foreign Branch**

1 First Commercial
2 Krung Thai
3 Bank of China
4 Mega
5 ICBC
6 Taiwan
7 Bangkok
8 Kasikorn
9 Mizuho
10 Vietnam
11 Industrial bank of korea

**21 Subsidiary Banks**

1 Cambodian
2 Public
3 May Bank
4 J Trust Royal
5 Advanced Bank of Asia
6 Invest. & Devel.
7 Shinhan
8 RHB Bank
9 CIMB
10 SACOM
11 Hong Leong
12 Cathay
13 Union
14 Phillip
15 SHB
16 Bred
17 DGB
18 Woori
19 MB Bank
20 KB Prasac
21 AMK

### 7 Specialized Banks

**3 Locally Incorporated**

1 ANCO
2 Evergrowth
3 Daun Penh

**4 Foreign Banks**

1 PHSME
2 KB Daehan
3 Aeon
4 Southern Capital

### 5 Representative Offices

1 Standard Chartered
2 Joint Stock Commercial
3 Sumitomo Mitsui
4 Shanghai
5 Export-Import

### 177 MICROFINANCE & RURAL CREDIT INSTISTUTION

**4 MDIs**

1 AMRET
2 LOLC
3 Mohanokor

**85 MFIs**

1 Seilanithih
2 Welcome
3 Maxima
4 Intean
5 Nong Hyup
6 Farmer
7 First Finance
8 Y.C.P
9 Samrithisak
10 Camma
11 Khemarak
12 Prime MF
13 Sonatra
14 Chamroeun
15 Active People
16 Bayon Credit
17 Borribo
18 Queen
19 City
20 Amatak
21 Sachak
22 ORO
23 Niron
24 Delta
25 Century
26 BAMC
27 PiphupThmey
28 Serey Oudom
29 Sambath
30 BNKC
31 Bamboo
32 Sahakrinpeap
33 Chailease royal
34 TBB
35 Royal
36 Sunny
37 Funan
38 Samporn Samakum
39 Samaky
40 Labor Care
41 CAM Capital Public
42 Kongkea Capital
43 Futaba
44 Idemitsu
45 Mothers
46 Sahaka
47 Golden Cash
48 Chokchey
49 Sabay
50 Jet's Cash Box
51 LED
52 L B P
53 Prasethpheap
54 T & Go
55 Anakut
56 Grow
57 Baitang
58 Mia
59 Leng Navatra
60 Vithey
61 Trop Khnhom
62 Khmer Capital
63 PG Development
64 JC
65 CMK
66 Rolya
67 LCH
68 Family
69 Propey
70 Sixty-Six
71 G B
72 Evergreen
73 Y.L.P
74 Sawad Rung Reung
75 Mango
76 Corich
77 Vivath Golden
78 Side Hustle
79 Soksan
80 AMZ
81 JACCS
82 East Micro Plc
83 RAFCO
84 HFC
85 Rich Avenue

**89 RCIs**

1 Chou Chivorn
2 Ministry of Rural
3 Bovor
4 Peayorb Finance
5 CEN Finance
6 Mittapheap
7 L.E.D.A Capital
8 DAIKOU
9 Preahkhan Aphivath
10 Krepo Finance
11 V.P Dec
12 Sereysuosdey Peanech
13 Chor Meyjing
14 Hykean Capital
15 Kon Khmer Mongkul
16 Mean Chey Credit
17 Brosear
18 Meakea
19 KPCA
20 Dako
21 Samnang Protebatkar
22 Smile Capital
23 Kunapheap
24 Samreth Pech
25 B.Y.G Finance
26 Quick Amatak
27 LH
28 Baytang
29 Chum Samnang
30 CAM
31 Enteam Easy
32 Morodok Aphivath
33 Kalyan Aphivath
34 Virakboth
35 ECK
36 Phka Chhouk
37 K.K.C.M
38 RADOCHICO
39 Prasithpheap Credit
40 Global Lending
41 LDA
42 Intean Neary
43 Pidaur Grow
44 Sky Light
45 Kroursa Ennatean
46 Amatak Rongroeng
47 Kuntheam
48 Sambo Trop
49 Tybotta
50 Right Smart
51 Angkor Chorpoan
52 Kakkorb
53 Preah Chan
54 ONO
55 FHF Capital Plc
56 CamFund Prathna
57 Mamede
58 Vireaksac
59 Racha
60 Aneaktean Molathan
61 Samrorb Samruol
62 Pishnuka
63 Prac
64 Lichou Capital
65 A.C.L.P.L
66 Punleu Snam Nhor Nhem
67 Metta
68 FT Cash Express Plc
69 Reaksmey Chey Chumneas
70 Reakreay
71 C.K.L.S
72 Unitrust
73 Crystal
74 S.B.E
75 ACABAR
76 Rithy
77 Samathor
78 Partner in Compassion Fund
79 Reahou
80 Sovannaphum Social Dev
81 Dhitemah
82 S.M.E.S ECO
83 Phanitda
84 OCKENDEN Metrei Entean
85 Right Place Rise Up
86 Hope Fund
87 Morakot
88 We Service
89 OUDONG

### NBC Provincial Branch

1 Phnom Penh
2 Kampong Cham
3 Sihanouk
4 Siemreap
5 Battambang
6 Banteay Meanchey
7 Svay Rieng
8 Kandal
9 Kampot
10 Kampong Thom
11 Pursath
12 Kampong Speu
13 Koh Kong
14 Ratanakiri
15 Prey Veng
16 Takeo
17 Kampong Chhnaing
18 Preah Vihear
19 Kratie
20 Stung Treng
21 Mondolkiri

### OTHERS BUSINESS

**Money Changer: 3,376**

Phnom Penh: 91
- License: 33
- Authorisation: 58

Provincial: 3,285
- License: 5
- Authorisation: 3,280

**12 Financial Leasing**

1 Tonle Finance
2 Mega Leasing
3 Suosdey
4 KK Fund Leasing
5 TOYOTA Tsusho
6 Chailease Royal
7 Komatsu Leasing
8 Kubota Leasing
9 L O D Leasing
10 Icare Leasing
11 Forward Leasing
12 We Service Leasing

**4 Third Party Processor**

1 Western Union
2 Money Gram
3 Dandelion Payment
4 Novus Technologies

**30 Payment Service Institutions**

1 True Money
2 Ly Hour Pay Pro
3 Pi Pay
4 Asia Cash Express
5 Seatel Financial Service
6 ARBITRARY PAY
7 Edeel
8 Ipay88
9 Bongloy Payments
10 Tian Xu International Technology
11 Huione Pay
12 E-Money Payment Solutions
13 Dragon fly
14 Dynamic
15 Dara Sakor
16 Bai Sen Technology
17 AETRINO GLOBAL
18 Paragon Payment
19 LM pay
20 One Pay Plc
21 Lync Pay Payment
22 U-Pay Digital
23 Starpay Fintech
24 Lanton International
25 Wing Money
26 Clik Payment
27 Sunpay
28 Cai Fu Tong
29 Payon
30 Jin Hong Zhen

**1 Credit Bureau**

1. CBC